June-2008.qxd 5/21/2008 11:12 AM Page 1

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១ ថ្ងៃទី០១-៣០ ខែមិថុនា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ១០

## មាតិកា




វិញ្ញាណក្ខន្ធលោកទើពអ៊ឹម និងមរណសាក្សី ទំព័រ ៧





អង្គការជេអេសស៊ី ចូលរួមលើកកម្ពស់តម្លៃជនពិការ ទំព័រ ៨





ស្នាដៃកែច្នៃសំរាមប្លាស្ទិក ទំព័រ ១៤


# តើយុវវ័យធ្វើអ្វីជាការកំសាន្ត របស់ពួកគេនៅពេលទំនេរ?

ទំព័រទី១០...







កម្មវិធីវិទ្យុ



**អេម៉ាន្ញូអែល** សំឡេងពីព្រះសហគមន៍កាតូលិក!

**ភ្នំពេញ : FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
**បាត់ដំបង : FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
**សៀមរាប: FM 102.5 Mhz** ១០:០០-១១:០០ ថ្ងៃ សៅរ៍/អាទិត្យ
**កំពង់ធំ : FM 88.5 Mhz** ម៉ោង ១២:០០-១២:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
**កំពង់ចាម : FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
**ក្រុងព្រះសីហនុ : FM 100.5 Mhz** ម៉ោង៦:០០-៧:០០ យប់ថ្ងៃសៅរ៍
**កំពត : FM 92.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

June-2008.qxd 5/21/2008 11:12 AM Page 2

# រូបថតសម្រាប់ខែនេះ



លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អេមីល ដេតម្ប ធ្វើអគ្គសញ្ញាលាបថ្វាសឱ្យដល់យុវជន យុវនារី ៦៣នាក់ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច ភ្នំពេញ កាលពីថ្ងៃទី១១ ឧសភា។ លោកអភិបាលបានលើកទឹកចិត្តបងប្អូនឱ្យរស់នៅតាមជំនឿ និងតាមព្រះបន្ទូលព្រះយេស៊ូ។ **(ឆ្វេង)**

កាយវិការក្នុងពិធីរំឭកវិញ្ញាណក្ខន្ធអ្នកស្លាប់ក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ដែលប្រារព្ធឡើងនាថ្ងៃទី២០ ឧសភា នៅសារមន្ទីរប្រវត្តិសាស្ត្រជើងឯក។ ២០ ឧសភា ១៩៧៥ ប៉ុលពតបានចេញគោលការណ៍លុបបំបាត់ទីផ្សារ សាសនា និងបង្កើតផ្ទះបាយរួម...។ **(ក្រោម)**



ទន្ទឹមនឹងសន្ទុះនៃការអភិវឌ្ឍនីរីកចម្រើននៅក្រុងភ្នំពេញ ប្រជាជនមួយចំនួនរស់នៅក្នុងភាពក្រីក្រនៅឡើយ។ គេរកប្រាក់ចំនួលមួយថ្ងៃសម្រាប់តែមួយថ្ងៃប៉ុណ្ណោះ។ តួយ៉ាងបុរសម្នាក់នេះប្រកបរបរដេរស្បែកជើងចល័ត ដែលអាចរកប្រាក់ចំនួល ១០០០០រៀល ក្នុងមួយថ្ងៃសម្រាប់គ្រួសារសមាជិក ៨នាក់របស់គាត់។ **(ក្រោម)**




ដំណើរទស្សនកិច្ចរបស់គ្រីស្តបរិស័ទមកពីព្រះសហគមន៍បឹងទំពុន និងគីរីវង្ស ទៅកាន់ព្រះសហគមន៍ចំការទៀង កាលពីថ្ងៃទី១៨ ឧសភា ដើម្បីស្វែងយល់ និងរៀនស្គាល់គ្នាទៅវិញទៅមក។ **(ក្រោម)**



ពិធីថ្វាយអភិបូជារួមគ្នារវាងគ្រីស្តបរិស័ទមកពីព្រះសហគមន៍បឹងទំពុន គីរីវង្ស និងចំការទៀង ប្រមាណ ២០០នាក់ នៅព្រះសហគមន៍ចំការទៀង នៅថ្ងៃបុណ្យព្រះត្រៃឯក តាមប្រតិទិនព្រះសហគមន៍កាតូលិកកាលពីថ្ងៃទី១៨ ឧសភា។ **(ឆ្វេង)**



Photos : L. Sovanna

June-2008.qxd 5/21/2008 11:12 AM Page 3



# ការកំសាន្ត យុវជនគួរធ្វើឱ្យមានប្រយោជន៍



Photo : L. Samphors

លោកលី សុវណ្ណា ចាងហ្វាងការផ្សាយអ្នកនាំសារ

ស្រាវជ្រាវពិភពថ្មី មានទំនាក់ទំនងល្អជាមួយអ្នកដទៃ បង្កើនចំណេះដឹង ធ្វើដំណើរកំសាន្ត-លំហែកាយ បង្កើតគ្រួសារ មានជំនាញអាជីព ទាំងនេះជាក្ដីសុបិន និងជាការខិតខំប្រឹងប្រែងស្វែងរករាល់ថ្ងៃរបស់យុវជនក្មេងៗ សព្វថ្ងៃនេះ។

បើតាមទិន្នន័យជំរឿនកម្ពុជាចុងក្រោយ បានឱ្យដឹងថា ៦២% នៃប្រជាជនកម្ពុជាសរុប មានអាយុក្រោម២៤ឆ្នាំ ដែលនេះជាសក្ដានុពលធនធានមនុស្សដ៏ខ្លាំងក្លា ក្នុងការអភិវឌ្ឍន៏ប្រទេស តាមរយៈការចូលរួមសកម្មភាពពួកគេក្នុងវិស័យកសិកម្ម និងវិស័យនានា។ "ការលំហែកាយយុវជន" មានសារៈសំខាន់ជាខ្លាំងដើម្បីអភិវឌ្ឍខាងចិត្តសាស្ត្រ ចំណេះដឹង និងរីកលូតលាស់រូបរាងកាយរបស់ពួកគេនៅគ្រប់សង្គមទាំងអស់ នេះបើតាមរបាយការណ៏នៃអង្គការសហប្រជាជាតិស្ដីពីយុវជន។ ប្រទេសកម្ពុជា គួរចាប់ផ្ដើមចោទសួរពីរបៀបដែលយុវជនបានធ្វើ នៅពេលទំនេរ។ តើកិច្ចការនេះអាចប្រព្រឹត្តិទៅបានប្រកបដោយផាសុខភាពដែរឬទេ? តើយុវជនខ្មែរមានរបៀបមួយដ៏សមរម្យដើម្បីអភិវឌ្ឍសមត្ថភាពខ្លួន តាមរយៈការភ្ញាក់រឭកយល់ដឹងអំពីអត្ថប្រយោជន៏នៃការកំសាន្តហើយឬនៅ? ជារឿយៗ យើងអស់សង្ឃឹមនៅពេលឃើញយុវជនក្មេងៗ ចំណាយពេលទំនេរ ទៅលេងបៀ ផឹកស្រា ឬខ្ជិលមិនធ្វើអ្វីទាល់តែសោះ។

ចាប់ពីថ្ងៃអង្គារទី១៥ ដល់ថ្ងៃអាទិត្យទី២០ កក្កដា ឆ្នាំ២០០៨ ទិវាយុវជនពិភពលោក ដ៏ធំបំផុត រៀបចំដោយព្រះសហគមន៏កាតូលិកនឹងធ្វើនៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។ ទិវានេះគឺមានការចូលរួមពីយុវជន គ្រប់ជាតិសាសន៏ និងជំនឿសាសនាមកពីជុំវិញពិភពលោកប្រមាណ១២៥០០០នាក់។ទិវាយុវជនពិភពលោកបានផ្ដើមគំនិតដោយសម្ដេចបាបយ៉ូហាន ប៉ូលទី២ នៅឆ្នាំ១៩៨៤ ដែលបានផ្ដល់ផលប្រយោជន៏ច្រើនដល់យុវជនគ្រប់ជាតិសាសន៏។ ប្រទេសកម្ពុជានឹងបញ្ជូនយុវជន ដែលមកពីគ្រប់ខេត្តក្រុងទាំងអស់ចំនួន ៤៥នាក់ ទៅចូលរួមទិវាយុវជនពិភពលោកឆ្នាំ២០០៨នេះផងដែរ។ **លោកលី សុវណ្ណា**

ប្រព័ន្ធផ្សព្វផ្សាយព័ត៏មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com;
Website : www.catholiccambodia.org;
ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ។
ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។
Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៏មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៩ ថ្មី ដែលជាចម្រៀងពណ៏នាអំពីតង្វាយដែលថ្វាយទៅព្រះជាម្ចាស់។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ ប្រសិនប្រិយមិត្តមានចំណាប់អារម្មណ៏ចង់ជាវនោះ សូមទំនាក់ទំនងទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។

## មណ្ឌលផ្សព្វផ្សាយព័ត៏មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៏មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងអស់គិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : ០១២ ៣៧៧ ៤៦០។

### សារសម្រាប់មិត្តអ្នកអាន!

បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្ដល់នូវចម្លើយដោយក្ដីរីករាយ។



**សេចក្ដីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយនិងចំណេញច្រើនសូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។
បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការ ក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។

June-2008.qxd 5/21/2008 11:12 AM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

## ថ្ងៃអាទិត្យទី៩ ក្នុងរដូវធម្មតា (ត្រូវនឹងថ្ងៃទី០១ មិថុនា ឆ្នាំ២០០៨)

(ម៉ាថាយ ៧,២១-២៧) សាវ័កព្រះយេស៊ូដ៏ពិតប្រាកដ មិនមែនជាអ្នកដែលគ្រាន់តែអធិដ្ឋានថា "ឱ! ព្រះអម្ចាស់! ឱ! ព្រះអម្ចាស់!" ប៉ុណ្ណោះទេ គឺជាអ្នកដែលធ្វើតាមព្រះហឫទ័យព្រះបិតាផងដែរ ។ បើយើងមិនយល់ពីព្រះហឫទ័យព្រះអង្គ អ្វីដែលយើងធ្វើគ្មានប្រយោជន៍នោះឡើយ ។ តើយើងទាំងអស់គ្នាព្យាយាមអានព្រះបន្ទូលហើយឬនៅ? តើយើងទាំងអស់គ្នា សាកល្បងស្វែងយល់ និងអធិដ្ឋានក្នុងនាមព្រះជាម្ចាស់ ហើយនឹងបំពេញកិច្ចការព្រះអង្គដែរឬទេ? គ្រីស្តបរិស័ទដែលមិនប្រព្រឹត្តិតាមព្រះបន្ទូលល្អ គឺប្រៀបបាននឹងមនុស្សឆោតល្ងង់ម្នាក់ ដែលបានសង់ផ្ទះលើដីខ្សាច់ ហើយក្រោយមក ក៏បាក់បែកខ្ទេចអស់គ្មានសល់ ។ ចូរយើងទាំងអស់គ្នាកសាងផ្ទះនៅលើផ្ទាំងថ្ម ដែលទោះបីជាមានខ្យល់បក់បោកខ្លាំងយ៉ាងណាក៏ដោយ ក៏ផ្ទះមិនរលំដែរ ពីព្រោះមានគ្រឹះដែលជាព្រះយេស៊ូគ្រីស្ត ។

## ថ្ងៃអាទិត្យទី១០ ក្នុងរដូវធម្មតា (ត្រូវនឹងថ្ងៃទី០៨ មិថុនា ឆ្នាំ២០០៨)

(ម៉ាថាយ ៩,៩-១៣) ព្រះបន្ទូលដំណឹងល្អថ្ងៃនេះ ជួយយើងយល់អំពីជីវិតលោកម៉ាថាយ ជាអ្នកយកពន្ធដែលបានត្រៀមខ្លួនដើរតាមព្រះយេស៊ូ ហើយចុះចំណែកយើងវិញ តើបានត្រៀមខ្លួនហើយឬនៅ? លោកម៉ាថាយ ជាបុរសអ្នកយកពន្ធម្នាក់ មិនសាកសមធ្វើជាសាវ័ករបស់ព្រះយេស៊ូទេ ព្រោះគាត់ត្រូវបានគេគិតថា ជាជនក្បត់ជាតិសាសន៍ និងសាសនា ។ យើងចូលចិត្តវាយតម្លៃមនុស្សសំបកក្រៅថាអាក្រក់ ផ្ទុយពីព្រះយេស៊ូ ។ ពេលព្រះយេស៊ូសោយព្រះស្ងោយនៅផ្ទះលោកម៉ាថាយ ខាងគណៈផារីស៊ី ក៏រិះគន់ព្រះអង្គ ដោយសារព្រះអង្គគង់នៅផ្ទះមនុស្សបាប ។ ចំណែកព្រះយេស៊ូក៏មានព្រះបន្ទូលថា : "មានតែអ្នកជំងឺប៉ុណ្ណោះទេ ដែលត្រូវការគ្រូពេទ្យ" ។ ព្រះយេស៊ូមិនចង់បានយញ្ញបូជាទេ គឺចង់បានតែសេចក្តីមេត្តាករុណាប៉ុណ្ណោះ ។

## ថ្ងៃអាទិត្យទី១១ ក្នុងរដូវធម្មតា (ត្រូវនឹងថ្ងៃទី១៥ មិថុនា ឆ្នាំ២០០៨)

(ម៉ាថាយ ៩,៣៦-១០,៨) ថ្ងៃនេះព្រះយេស៊ូមានព្រះហឫទ័យអាណិតអាសូរមហាជន ពីព្រោះអ្នកទាំងនោះអស់កម្លាំងប្រៀបបីដូចជាចៀមដែលគ្មានអ្នកគង្វាលថែទាំ ។ ដូចសព្វថ្ងៃនេះ មានមនុស្សរាប់ពាន់នាក់អស់សង្ឃឹម គ្មានទិសដៅនៅក្នុងជីវិត ហើយគ្មានអ្នកដឹកនាំឱ្យត្រឹមត្រូវ ។ ព្រះយេស៊ូជ្រាបថា : "ស្រូវដែលត្រូវច្រូតមានច្រើនណាស់ តែអ្នកច្រូតមានចំនួនតិចពេក" ។ ព្រះយេស៊ូបានត្រាស់ហៅសាវ័កទាំង១២នាក់ ដើម្បីប្រកាសថា : "ព្រះរាជ្យនៃស្ថានបរមសុខនៅជិតបង្កើយ" ។ តើអស់អ្នករាល់គ្នាបានត្រៀមខ្លួនចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់ហើយឬនៅ?

## ថ្ងៃអាទិត្យទី១២ ក្នុងរដូវធម្មតា (ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៨)

(ម៉ាថាយ ១០,២៦-៣៣) "ចូរកុំខ្លាច..." ជាដំបូន្មានរបស់ព្រះយេស៊ូ ។ ព្រះគម្ពីរដំណឹងល្អថ្ងៃនេះ និយាយពីសេចក្តីខ្លាចរបស់សាវ័កដែលមិនហ៊ានធ្វើជាសាក្សីរបស់ព្រះយេស៊ូ ។ ព្រះយេស៊ូក៏លើកទឹកចិត្តពួកគេថា : "ចូរកុំខ្លាច..." ។ ភាពរន្ធត់ធ្ងន់ធ្ងរជាងគេ គឺនៅពេលយើងបោះបង់ចោលឆន្ទៈធ្វើជាសាក្សី ហើយនិងក្បត់ព្រះយេស៊ូ មិនមែនដោយសារខ្លាចគេសម្លាប់យើងនោះទេ ។ អស់អ្នកដែលបានទទួលពិធីជ្រមុជទឹក គឺធ្វើជាសាក្សីរបស់ព្រះយេស៊ូតាមរយៈពាក្យសំដី កាយវិការ និងរស់នៅជាគំរូដ៏ល្អ ។

## បុណ្យឱឡារិកសន្តសិលា និងសន្តប៉ូល (ត្រូវថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៨)

(ម៉ាថាយ ១៦,១៣-១៩) ថ្ងៃនេះព្រះសហគមន៍ប្រារព្ធពិធីបុណ្យដ៏ឱឡារិក គ្រីស្តទូតសិលា និងប៉ូល ដែលជាគ្រឹះមូលដ្ឋាននៃព្រះសហគមន៍ដំបូង ។ ព្រះសហគមន៍រួបរួមគ្នាអធិដ្ឋានថា : "ចូរគ្រីស្តទូតសិលាប្រកាសដំណឹងល្អទៅប្រជាជនអ៊ីស្រាអែលជាមុន រីឯគ្រីស្តទូតប៉ូលក៏ប្រកាសដំណឹងល្អដល់សាសន៍ដទៃ ។ គ្រីស្តទូតសិលា គឺតំណាងដោយសម្តេចប៉ាបដែលនាំឱ្យព្រះសហគមន៍រួបរួមគ្នាតែមួយ ។ គ្រីស្តទូតសិលាជាអ្នកដែលព្រះយេស៊ូប្រគល់កូនសោព្រះរាជ្យនៃស្ថានបរមសុខ នៅពេលលោកសិលាប្រកាសជំនឿថា : "លោកគឺជាព្រះគ្រីស្ត ជាព្រះបុត្រារបស់ព្រះបិតា ដែលមានព្រះជន្មគង់នៅ" ។ ចំណែកគ្រីស្តទូតប៉ូលវិញ គឺតំណាងឱ្យបេសកកម្មព្រះសហគមន៍នៅគ្រប់ទីកន្លែង ។ចូរយើងទាំងអស់គ្នាអធិដ្ឋានសម្រាប់ព្រះសហគមន៍ទាំងមូល និងសម្តេចប៉ាប ដែលជានិមិត្តរូបនៃការរួបរួមគ្រីស្តបរិស័ទទាំងឡាយ ហើយចំពោះអស់អ្នកដែលកំពុងរកឃើញរបៀបថ្មីក្នុងការប្រកាសព្រះរាជ្យស្ថានបរមសុខដល់បងប្អូនគ្រប់ទីកន្លែង ។

**លោកបូជាចារ្យអ្នូមែរ ហ្ស៊ីរ៉ាល់ដូ**

## សម្រាប់កុមារ



Photo: DR

សួស្តីប្អូនៗ ក្នុងលេខនេះ អ្នកនាំសារសូមនាំឱ្យស្គាល់ធម៌អធិដ្ឋានមួយ គឺ "ធម៌ ! ឱព្រះបិតាយើងខ្ញុំ"។ នៅក្នុងធម៌អធិដ្ឋាននេះ មានបីផ្នែកធំៗ គឺទី១ យើងទាំងអស់គ្នាថ្វាយបង្គំព្រះជាម្ចាស់ជាព្រះបិតារបស់យើង។ ទី២ យើងថ្វាយព្រះពរចំពោះព្រះជាម្ចាស់។ ទី៣ យើងអង្វរព្រះបិតា។

សូមយើងសូត្រទាំងអស់គ្នា :

១-ឱ ! ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ ! គឺយើងទាំងអស់គ្នាថ្វាយបង្គំព្រះជាម្ចាស់ ជាព្រះបិតារបស់យើង ដូចកូនថ្វាយបង្គំឪពុកដោយបែរមុខទៅរកគាត់ដែរ។

២-យើងថ្វាយព្រះពរចំពោះព្រះជាម្ចាស់ "សូមឱ្យមនុស្សលោកស្គាល់ព្រះនាម" មានន័យថា យើងសូមព្រះអង្គបង្ហាញឱ្យមនុស្សលោកស្គាល់ព្រះអង្គ។ "សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់" សូមព្រះអង្គយាងមកគ្រងរាជ្យលើមនុស្សទាំងអស់ គឺឱ្យមានយុត្តិធម៌ សន្តិភាព និងសេចក្តីសុខសាន្ត ឱ្យមនុស្សរួបរួមគ្នាលើផែនដីទាំងមូលក្រោមអំណាចរបស់ព្រះអង្គ។ "សូមឱ្យព្រះហឫទ័យរបស់ព្រះអង្គបានសម្រេច..." គឺសូមឱ្យមនុស្សលោករួបរួមគ្នាជាមួយព្រះអង្គដោយចិត្តស្រឡាញ់ និងបានសុខសាន្ត។ យើងឱ្យសេចក្តីស្រឡាញ់របស់ព្រះអង្គគ្រងរាជ្យលើគ្រីស្តបរិស័ទ គឺឱ្យយើងស្រឡាញ់ព្រះអង្គ។

៣-យើងអង្វរព្រះបិតាមានបីយ៉ាង គឺ

-អាហារ : អាហារសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអាហារបំភ្លឺជីវិតយើងដែលបង្ហាញឱ្យយើងស្គាល់ អ្វីល្អ អ្វីអាក្រក់។ អាហារក៏ជាព្រះកាយព្រះគ្រីស្តដែរ។

-សូមព្រះអង្គលើកលែងទោស : យើងសូមព្រះជាម្ចាស់អត់ទោសឱ្យយើង ព្រោះព្រះអង្គស្រឡាញ់យើងហួសពីការស្មាន។ សូមឱ្យយើងចេះអត់ទោសឱ្យអ្នកដទៃដែរ ទើបព្រះអង្គអត់ទោសឱ្យយើងដែរ។ ដូច្នេះសូមអធិដ្ឋានអង្វរព្រះអង្គជារៀងរាល់ថ្ងៃ។

-កម្លាំង : ដោយសារយើងជាមនុស្សមានភាពទន់ខ្សោយ និងខ្វះកម្លាំង នោះយើងងាយចាញ់ការល្បួងទាំងឡាយដែលនៅជុំវិញខ្លួន។

លី សុវណ្ណា

June-2008.qxd 5/21/2008 11:12 AM Page 5

# ព្រឹត្តិការណ៍ប្រចាំខែ



Photo: DR

## ព្រះឆាយាល័ក្ខណ៍ ព្រះបរមនាថ សីហមុនី លើប្រាក់រៀល

រដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យចរាចរក្រដាស់ប្រាក់២ម៉ឺនថ្មី ដែលមានរូបព្រះឆាយាល័ក្ខណ៍ ព្រះបរមនាថ នរោត្តម សីហមុនី កាលពីថ្ងៃ១២ ឧសភាដើម្បីអបអរថ្ងៃបុណ្យចម្រើនព្រះជន្មរបស់ព្រះមហាក្សត្រ ។ សម្តេចនាយករដ្ឋមន្ត្រីហ៊ុន សែន បានប្រកាសកាលពីព្រឹក ថ្ងៃទី៩ ឧសភា ក្នុងពិធីបុណ្យបញ្ចុះសីមាក្នុងវត្តក្រពើហា ខេត្តកណ្តាលថា : "ក្រដាស់ប្រាក់ ២០ ០០០ រៀលថ្មីនេះ គឺជាការគោរពរបស់រដ្ឋាភិបាល និងខ្ញុំព្រះករុណា ដែលក្នុងនាមជានាយករដ្ឋមន្ត្រី និងរបស់ធនាគារជាតិកម្ពុជា" ។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានបន្តថា មុននឹងបោះពុម្ពផ្សាយប្រភេទក្រដាសប្រាក់ថ្មីនេះ លោកបានសុំព្រះរាជយោបល់ពីអតីតព្រះមហាក្សត្រផងដែរ ។ ក្នុងការដាក់ឱ្យចរាចរក្រដាសប្រាក់ពីម៉ឺនថ្មីនេះ សម្តេចហ៊ុន សែន បាននិយាយការពារជាមុនថា កម្ពុជាសព្វថ្ងៃមិនមានអតិផរណាប្រាក់រៀលលើទីផ្សារនោះទេ ដោយឡែកគេកំពុងតែខ្វះប្រាក់រៀលទៅវិញ ។

## គណបក្សនយោបាយចូលរួមបោះឆ្នោតជាតិថយចុះ

គណបក្សនយោបាយ ១២ បានមកចុះឈ្មោះជាផ្លូវការក្នុងបញ្ជីគណៈកម្មាធិការរៀបចំបោះឆ្នោត ( គជប ) កាលពីថ្ងៃ ១២ឧសភា ។ លោកខន កែវមនោ នាយករងនៃ នាយកដ្ឋានព័ត៌មានសាធារណៈ គជប បានឱ្យដឹងនៅថ្ងៃទី១៩ នេះថា គជបបានទទួលស្គាល់ គណបក្សចំនួន១០ ជាផ្លូវការ ហើយសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ នាថ្ងៃទី២៧ កក្កដា ខាងមុខនេះ ក្នុងនោះរួមមានគណបក្សប្រជាជនកម្ពុជា គណបក្សសមរង្ស៊ី គណបក្សហ្វុនស៊ីនប៉ិច គណបក្សខ្មែរឈប់ក្រ គណបក្សខ្មែរសាធារណរដ្ឋ គណបក្សនរោត្តមរណឫទ្ធិ គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ គណបក្សសិទ្ធិមនុស្ស គណបក្សសង្គមយុត្តិធម៌ និងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ។ ដោយឡែកគណបក្សសង្គមខ្មែរនិយមត្រូវបានគជបបដិសេធ និងគណបក្សប្រជាធិបតេយ្យខ្មែរ គជបទុកពេល ៥ថ្ងៃឱ្យកែសម្រួលចំនុចមួយចំនួន ។ សូមរំឭកថា កាលពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ២០០៣ មានគណបក្ស ២៣ចូលរួម ។

## អតិផរណានឹងធ្លាក់ចុះបន្តិចនៅចុងឆ្នាំ ២០០៨

ក្រុមអ្នកសេដ្ឋកិច្ចកម្ពុជា វាយតម្លៃថា កម្រិតអតិផរណានឹងថយបន្តិចនៅចុងឆ្នាំនេះ ។ លោកបណ្ឌិតហង្សជួនណារ៉ុន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្យាករថា អតិផរណានឹងចុះទៅវិញបណ្តើរៗ បន្តិចម្តងៗរហូតចុងឆ្នាំ២០០៨ ក្រោយពេលដែលកសិផលសព្វសារពើមានច្រើននៅលើទីផ្សារ ។ លោកបណ្ឌិតបន្ថែមថា : "យ៉ាងហោចអតិផរណានឹងចុះមួយខ្ទង់នៅចុងឆ្នាំ ទល់នឹងអតិផរណាសព្វថ្ងៃគឺ១០%" ។ ដោយឡែកសេដ្ឋកិច្ចវិទូសុខ ហាច នាយកវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា មានជំនឿដែរថា កម្រិតអតិផរណានឹងថយចុះបន្តិចម្តងៗរហូតដល់ចុងឆ្នាំ ។

**រស់ ឱណា**

## អសប ព្យុះនៅភូមាធ្វើឱ្យពលរដ្ឋ ១,៥លាននាក់ ទទួលរងគ្រោះ



Photo: DR

អង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថា ព្យុះដែលបោកបក់នៅភូមាធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រជាជនប្រមាណ ១,៥លាននាក់ ។ តាមទីភ្នាក់ងារព័ត៌មានបាន អេភី បានឱ្យដឹងថា ព្យុះណាហ្ស៊ីស ( **Nargis** ) ដែលបោកបក់ដីសណ្តអ៊ីរ៉ាវ៉ាឌីនៅក្នុងល្បឿន ១៩០គីឡូម៉ែត្រនៅក្នុង ១ម៉ោង ជាមួយទឹករលកកម្ពស់ ៣,៧ម៉ែត្រផងនោះ ត្រូវបានគេជឿថា បានសម្លាប់ជីវិតពលរដ្ឋអស់ជាច្រើនពាន់នាក់ តែអាជ្ញាធរយោធាភូមា មិនបានប្រកាសពីតួលេខជនរងគ្រោះពិតប្រាកដ ក្នុងគ្រោះមហន្តរាយនេះឡើយ ។
ទូរទស្សន៍រដ្ឋភូមា បានអះអាង កាលពីថ្ងៃទី៦ ឧសភាថា ព្យុះនេះបានសម្លាប់ជីវិតមនុស្សត្រឹមតែ ៧៨០០០នាក់ និងបាត់បង់ខ្លួនប្រមាណជា ៤២១១៩នាក់ប៉ុណ្ណោះ ប៉ុន្តែសម្រាប់តួលេខនៃការបាត់ខ្លួន និងអ្នកដែលបានបាត់បង់ជីវិតពិតប្រាកដ បើតាមអ្នកជំនាញការ បានអះអាងថា មានចំនួនច្រើនលើសនេះទៅទៀត ។
បើតាមលោកសារី វីឡារូសា ( **Shari Villarosa** ) ភារៈធារីស្ថានទូតអាម៉េរិកនៅក្នុងប្រទេសភូមាបានអះអាងថា ចំនួនអ្នកស្លាប់អាចមានចំនួនលើសពី ១០០០០០នាក់ ។

## គ្រោះថ្នាក់រថយន្តក្រុង មនុស្សស្លាប់ជិត ៣០នាក់នៅឥណ្ឌា

តាមទីភ្នាក់ងាររ៉យទ័រ បានឱ្យដឹងថា ឧប្បត្តិហេតុគ្រោះថ្នាក់រថយន្តក្រុងមួយនៅតំបន់កាស្មៀ ( **Kashmir** ) ប្រទេសឥណ្ឌា កាលពីដើមខែឧសភា បានសម្លាប់ជីវិតមនុស្សយ៉ាងហោច ៣០ នាក់ នៅពេលដែលរថយន្តរអិលធ្លាក់ផ្លូវចូលទៅក្នុងជ្រលងទន្លេ ។
លោកស៊ីយេដអ៊ិនណាយ៉ាទូឡា មន្ត្រីរដ្ឋាភិបាលឥណ្ឌាប្រចាំតំបន់នោះ អះអាងថា: "គ្រោះមហន្តរាយនេះបានសម្លាប់ជីវិតមនុស្សជិត៣០នាក់ ។ យើងក៏បានទាញយកសាកសពជនរងគ្រោះចំនួន ២៨នាក់ និងកំពុងព្យាយាមស្វែងរកបន្តទៀត" ។
នៅមុនពេលគ្រោះថ្នាក់ គេជឿជាក់ថា រថយន្តក្រុងនេះបានផ្ទុកមនុស្សទាំងអស់ចំនួនយ៉ាងហោចណាស់ក៏ ៤០នាក់ដែរ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែង សង្គ្រោះអ្នកដែលនៅមានជីវិត និងរុករកសាកសពកំពុងតែជួបនូវឧបសគ្គយ៉ាងខ្លាំង ដោយសារតែកន្លែងដែលធ្លាក់នោះ ស្ថិតនៅក្នុងតំបន់ជ្រលងភ្នំជ្រៅ ហើយណាមួយទៀតរថយន្តដែលធ្លាក់នោះត្រូវកប់ទៅក្នុងទន្លេផង ។ រថយន្តនេះបានក្រឡាប់ប៉ះជើងឡើងទៅលើ ហើយតួរបស់រថយន្តទាំងមូលបានត្រូវកប់ក្នុងទន្លេ ដែលគេឃើញតែកង់របស់វាប៉ុណ្ណោះ ។

**ខាន់ ភីរម្យ**

# យើងត្រូវជួយទុក្ខធុរៈអ្នកដទៃនៅពេលជួបគ្រោះអាសន្ន

**កែវ កញ្ញា**

ទឹកប្រាក់ប្រមាណជា ៥០០០ដុល្លារអាមេរិក ដែលព្រះសហគមន៍ភូមិភាគទាំង៣ ក្នុងប្រទេសកម្ពុជា ប្រមូលបានពីគ្រីស្តបរិស័ទតាំងតែពីឱកាសបុណ្យរំឭកព្រះវិញ្ញាណយាងមកកាលពីថ្ងៃអាទិត្យទី១១ ខែឧសភាមុននេះនៅតាមព្រះសហគមន៍នានាទូទាំងប្រទេសត្រូវបានបញ្ជូនទៅប្រទេសភូមា ។

លោកអេមីល ដេតម្ប អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា : "យើងចាប់អារម្មណ៍លើទុក្ខវេទនារបស់ពួកគេ មិនត្រឹមតែពាក្យសំដី និងការអធិដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែជួយទុក្ខធុរៈពួកគេ តាមរយៈការវិភាគទានផ្សេងៗតាមលទ្ធភាពដែលអាចធ្វើទៅបានដើម្បីបញ្ជាក់ថា យើងជាគ្រួសារតែមួយ" ។ ចំណែកឯលោកអន់តូនីសាមី អភិបាលមកពីព្រះសហគមន៍កំពង់ចាម បានបញ្ជាក់ថា : "ក្រុមគ្រីស្តបរិស័ទនីមួយៗនៃភូមិភាគកំពង់ចាមក៏បានរួបរួមគ្នាអធិដ្ឋាន និងប្រមូលថវិកាបានមួយចំនួន ដើម្បីជួយរួមរំលែកទុក្ខលំបាករបស់ប្រជាជនភូមាផងដែរ ។ ជាមួយគ្នានេះ លោកអភិបាលគីកេ នៃភូមិភាគបាត់ដំបងបានបង្ហាញចំណាប់អារម្មណ៍ថា : "រូបខ្ញុំសូមកោតសរសើរដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ ដែលចេះសាមគ្គីគ្នា និងជួយគ្នាក្នុងគ្រាមានអាសន្នអន់ក្រដូច្នេះ" ។



Photo: DR

ខ្យល់ព្យុះណាហ្គីសដ៏មហន្តរាយបោកបក់ក្នុងល្បឿន១៩០គម លើប្រទេសភូមាកាលពីថ្ងៃទី៥ ឧសភា បានបង្កឱ្យមានសោកនាដកម្មដ៏ធំធេងសម្រាប់ប្រជាជនភូមា

## សិក្ខាសាលាអំពីលក្ខន្តិកៈការអប់រំនៃព្រះសហគមន៍កាតូលិក



Photo: L. Samphors

លោក-អ្នកគ្រូ ចំនួន២២០នាក់ មកពីសាលារបស់ព្រះសហគមន៍កាតូលិកនាគ្រប់កម្រិត និងបុគ្គលិកអង្គការនានានៅក្នុងរចនាសម្ពន្ធ នៃព្រះសហគមន៍កាតូលិក បានចូលរួមក្នុងអង្គសិក្ខាសាលាមួយស្តីពីលក្ខន្តិកៈនៃការអប់រំ របស់ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ធ្វើនៅសាលាដុនបូស្កូ ផ្នែកនារីក្នុងសង្កាត់ទឹកថ្លា នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១ ខែឧសភាកន្លងទៅនេះ ។

អង្គសិក្ខាសាលានេះបានរៀបចំឡើងរយៈពេល៣ថ្ងៃ ដែលមានអ្នកស្រីក្លែរ លី គឺជាវាគ្មិនកិត្តិយស ។ អ្នកស្រី បានលើកឡើងអំពីបទពិសោធន៍របស់អ្នកស្រីខណៈពេលបង្រៀនសិស្សនៅឯវិទ្យាល័យថា អ្វីដែលសំខាន់សម្រាប់រូបគាត់ក្នុងនាមជាគ្រូ គឺចង់ឱ្យសិស្សទាំងអស់បញ្ចេញមតិនិងគំនិតរបស់ពួកគេជាជាងសូត្រអំពីទ្រឹស្តីរបស់អ្នកប្រាជ្ញផ្សេងៗ ។

**ឡុង សម្ផស្ស**

## គណៈកម្មការសុខភាពត្រូវបានបង្កើតនៅភូមិភាគភ្នំពេញ

យើងខ្ញុំសូមជម្រាបជូនដំណឹងដល់បងប្អូនទាំងអស់ឱ្យបានជ្រាបថា ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ក្រោមការណែនាំរបស់លោកអភិបាលអេមីល ដេតម្ប បានរៀបចំគណៈកម្មការដើម្បីទទួលអ្នកជំងឺ។

គណៈកម្មការនេះ យកចិត្តទុកដាក់នៅលើបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋក្រីក្រ និងបងប្អូនជាគ្រីស្តបរិស័ទក្នុងប្រទេសកម្ពុជា។ គណៈកម្មការនេះមានគោលបំណងចំបង គឺធ្វើការចែករំលែក និងផ្លាស់ប្តូរគំនិត និងបទពិសោធន៍ ទាក់ទងនឹងបញ្ហាសុខភាព ព្រមទាំងជួយសម្របសម្រួលរាល់កិច្ចការព្រះសហគមន៍ផងដែរ។ ដោយហេតុថា គណៈកម្មការរបស់យើងទើបតែចាប់បដិសន្ធិនោះ យើងសូមស្វាគមន៍នូវមតិយោបល់ និងគំនិតស្ថាបនាផ្សេងៗ ដើម្បីឱ្យគណៈកម្មការយើងខ្ញុំកាន់តែមានប្រសិទ្ធភាពនៅការងារជាក់ស្តែងថែមទៀត។

សម្រាប់ព័ត៌មានបន្ថែម ឬមានមតិយោបល់ផ្សេងៗនោះ សូមទំនាក់ទំនង : បងស្រី ប៉ោឡា មោជរ អ្នកសម្របសម្រួលកម្មវិធី ទូរស័ព្ទ : ០៩២ ៦៥៥៨៦០។ លោកវេជ្ជបណ្ឌិត ឈួន ឈឿត ជំនួយការអ្នកសម្របសម្រួលកម្មវិធី ទូរស័ព្ទ : ០៤២ ៣៩៧ ០៣១។ បងស្រីម៉ារីយ៉ា តេរ៉េស្សា ដាលីសាយ លេខាធិការ ទូរស័ព្ទ : ០១២ ៦០៤ ៦៨៤។

សូមអរគុណ !

## មណ្ឌលសន្ត យ៉ូហាន បាទីស្ត

-ជួយឱ្យយុវជនមានបទពិសោធន៍រួមគ្នា ដើម្បីឱ្យពួកគេមានការរីកចម្រើនទាំងខាងផ្លូវចិត្ត និងផ្លូវវិញ្ញាណ

-ជួយឱ្យយុវជនបានបន្តការសិក្សារហូតប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២

-អប់រំយុវជនឱ្យចេះជួយបម្រើព្រះសហគមន៍ និងសង្គមខ្មែរ

**តើប្អូនអាចចុះឈ្មោះតាមរបៀបណា ?**

-ប្អូនៗត្រូវសុំឯកសារបំពេញសំណុំបែបបទពីលោកបូជាចារ្យតាមព្រះសហគមន៍

-ត្រូវបំពេញសំណុំបែបបទឱ្យបានច្បាស់លាស់ រួចបិទរូបថត

-ថតចម្លងសៀវភៅតាមដាន (១ ច្បាប់)

-ឈប់ទទួលពាក្យនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៨

-ប្អូនដែលបានដាក់ពាក្យរួចហើយ ត្រូវមកធ្វើសម្ភាសន៍នៅថ្ងៃទី២៣-២៤ សីហា ឆ្នាំ២០០៨

-លទ្ធផលនឹងចេញនាថ្ងៃទី១ កញ្ញា ឆ្នាំ២០០៨

**សូមទំនាក់ទំនង** ជាមួយលោកឪពុក ប៊្រុយណូ អាសយដ្ឋាន ផ្ទះលេខ ៤៤ ផ្លូវ ២៨៩ ភ្នំពេញ ឬទូរស័ព្ទ : ០១៦ ៨៣១ ៦៨៣ ។

## បទយកការណ៍ព្រះសហគមន៍កាតូលិក

# រំឭកវិញ្ញាណក្ខន្ធលោកអភិបាលទេពអ៊ីម និងមរណសាក្សី

**សុជាតិ និងភីរុណ**

គ្រីស្តបរិស័ទប្រមាណជា ៣០០នាក់ នៃព្រះសហគមន៍កាតូលិកចំនួន៧ ក្នុងភូមិភាគបាត់ដំបង បានមកជួបជុំគ្នា នៅភូមិក្បាលស្ពាន ឃុំបត់ត្រង់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី៧ ខែឧសភា កន្លងទៅ ដើម្បីប្រារព្ធពិធីរំឭកវិញ្ញាណក្ខន្ធលោកប៉ូល ទេពអ៊ីម សុត្ថា អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង និងមរណសាក្សីមួយចំនួនទៀត ដែលត្រូវបានគេសម្លាប់ក្នុងសម័យខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩។

លោកស៊ីស៊ីល បូជាចារ្យទទួលខុសត្រូវ ព្រះសហគមន៍ ស្វាយស៊ីសូផុន មានប្រសាសន៍ថា: "នេះជាលើកទីមួយ ដែលព្រះសហគមន៍ជួបជុំប្រារព្ធពិធីដ៏មានអត្ថន័យនេះដើម្បីរំឭកដល់វិញ្ញាណក្ខន្ធលោកប៉ូល ទេពអ៊ីម សុត្ថា ជាអភិបាលនៃព្រះសហគមន៍កាតូលិកបាត់ដំបងពីដើម នៅទីកន្លែងដែលពួកខ្មែរក្រហមបានសម្លាប់លោក"។ តាមពិត លោកអភិបាលត្រូវគេសម្លាប់ ព្រោះតែសេចក្តីស្រឡាញ់ និងធ្វើជាសាក្សីរបស់ព្រះយេស៊ូនៅកម្ពុជា"។

ក្នុងពិធីរំឭកដល់លោកអភិបាលជាទីស្រលាញ់ បងប្អូនដែលធ្លាប់បានរស់នៅយ៉ាងជិតស្និទ្ធ ជាមួយនិងលោក បានសម្តែងនូវទឹកចិត្តរំភើប និងក្តុកក្តួល ជាខ្លាំង។ នៅក្នុងនោះ លោកស្រីដាំ ប្រាជ្ញា សមាជិកគណៈកម្មាធិការព្រះសហគមន៍កាតូលិកបាត់ដំបង បានរៀបរាប់ថា លោកអភិបាលហាក់ដូចជាដឹងមុននៅក្នុងអភិបូជាថ្ងៃអាទិត្យចុងក្រោយ លោកមានប្រសាសន៍ថា: "បន្តិចទៀត យើងទាំងអស់គ្នា នឹងមានពពួកកាចសាហាវ មកកាន់កាប់ប្រទេសយើងហើយ"នោះគឺពួកប៉ុលពតនេះឯង។លោកជាសាក្សីដ៏ប្រសើររបស់ព្រះយេស៊ូសម្រាប់យើង។

លោកគ្រួយ៉ាត គ្រីស្តបរិស័ទមួយរូបដែលបានស្គាល់លោកអភិបាលយ៉ាងជិតស្និទ្ធនោះ ក៏បញ្ជាក់បន្ថែមថា: "លោកអភិបាល ជាមនុស្សដ៏សាមញ្ញ និងក្រីក្របំផុត"។ លោកបានជួបជាមួយលោកអភិបាលមុនពេលស្លាប់។ លោកអភិបាលក៏ព្រួយបារម្ភខ្លាំងណាស់ ដោយសារនៅតាមផ្លូវ លោកឃើញពួកខ្មែរក្រហមបានសម្លាប់មនុស្សជាច្រើន។ចំណែកលោកគ្រួយ៉ាតបានសុំឱ្យលោកអភិបាលរត់ទៅព្រំដែនថៃតាមច្រកផ្សេង តែលោកពុំទៅព្រោះវាខុសច្បាប់។ លោកអភិបាលសម្រេចចិត្តទៅតាមផ្លូវជាតិលេខ៥ និងក៏ត្រូវគេសម្លាប់នៅភូមិក្បាលស្ពាននេះ"។

លោកតូតែត តំណាងពេញសិទ្ធិនៃលោកអភិបាលព្រះសហគមន៍កាតូលិកបាត់ដំបង ក៏មានប្រសាសន៍ឱ្យដឹងដែរថា: "សម្រាប់គ្រប់មរណសាក្សីទាំងអស់របស់ព្រះយេស៊ូ ដែលបានបង្ហូរឈាមដើម្បីព្រះអង្គជាគ្រាប់ពូជដ៏ល្អបំផុត រកអ្វីមកប្រៀបផ្ទឹមមិនបានសម្រាប់ជំនឿរបស់ព្រះសហគមន៍ព្រះអង្គ"។

អ៊ំស្រីឡួយ ដែលមកពីព្រះសហគមន៍និគម ក៏មានប្រសាសន៍ឱ្យដឹងដែរថា ពិធីរំឭកវិញ្ញាណក្ខន្ធរបស់លោកអភិបាលទេពអ៊ីម និងមរណសាក្សីផ្សេងៗ គឺល្អណាស់ ព្រោះអាចឱ្យកូនចៅក្រោយៗ បានស្គាល់ថា លោកទាំងអស់នោះជានរណា? បានធ្វើអ្វីខ្លះ? និងស្លាប់ដោយសារអ្វី? ដើម្បីជាគំរូសម្រាប់គេ។

### ប្រវត្តិលោកប៉ូលទេពអ៊ីម សុត្ថា

**លោកប៉ូល ទេពអ៊ីម សុត្ថា កើតនៅភ្នំពេញក្នុងឆ្នាំ១៩៣៤។ លោករៀននៅទេវវិទ្យាល័យនៅប្រទេសបារាំង និងនៅមហាវិទ្យាល័យ ទេវវិទ្យាក្រុងរ៉ូម។ លោកទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យកាតូលិកនៅឆ្នាំ១៩៥៩ ទទួលតំណែងជាអ្នកណែនាំគ្រីស្តបរិស័ទខ្មែរក្រុងភ្នំពេញនៅ "ព្រះវិហារព្រះមាតា"។ នៅថ្ងៃទី២៦ កញ្ញា ឆ្នាំ១៩៦៨ លោកទទួលភារកិច្ចមើលការខុសត្រូវលើភូមិភាគបាត់ដំបង ក្នុងនាមសម្តេចប៉ាប។ លោកត្រូវគេប្រហារជីវិតដោយគ្មានកំហុសនៅដើមខែឧសភា ឆ្នាំ១៩៧៥ នៅឃុំបត់ត្រង់ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។ សព្វថ្ងៃមាន លោកអភិបាលគីកេ ហ្វីការេដូ ទទួលមុខងារណែនាំព្រះសហគមន៍ភូមិភាគបាត់ដំបងបន្តពីលោកប៉ូល ទេពអ៊ីម សុត្ថា នៅឆ្នាំ២០០០។**



Photo: Br. Bong Bong

June-2008.qxd 5/21/2008 11:12 AM Page 8



# អង្គការជេអេសស៊ី ចូលរួមលើកកម្ពស់តម្លៃជនពិការ

**ឡុង សម្ផស្ស**


សកម្មភាពបង្រៀនក្នុងថ្នាក់មួយ របស់មជ្ឈមណ្ឌលបន្ទាយព្រាប

Photo : L. Samphors

ក្រោយពីសង្គ្រាម នៅប្រទេសកម្ពុជា មានសល់ជនពិការជាច្រើននាក់ ។ ដោយបានមើលឃើញអំពីការលំបាករបស់បងប្អូនពិការ ទើបទាំងរាជរដ្ឋាភិបាលរួមជាមួយនិងអង្គការនានាផងដែរ បានយកចិត្តទុកដាក់ក្នុងការជួយលើកកម្ពស់តម្លៃនៃជនពិការតាមរយៈការផ្តល់ជំនាញផ្សេងៗ ដល់ពួកគេសម្រាប់រស់នៅទៅអនាគត ។

លោកបូជាចារ្យ ហ៉ រ គី ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ បន្ទាយព្រាប នៃអង្គការជេអេសស៊ី ក៏មានប្រសាសន៍ថា: "អង្គការជេអេសស៊ី ជាអង្គការអន្តរជាតិ បង្កើតឡើងនៅឆ្នាំ១៩៨០ នៅជំរំជនភៀសខ្លួនឯព្រំដែនកម្ពុជា-ថៃ ។ អង្គការមានគោលបំណងជួយដល់ដំណើរការបង្រួបបង្រួមជាតិ សន្តិភាព យុត្តិធម៌ ហើយនិងអភិវឌ្ឍដល់ជនរងគ្រោះដោយសង្គ្រាម ដែលទទួលការគាបសង្កត់ និងធ្វើនិរទេសខ្លួន ក្រោយពេលបងប្អូនធ្វើមាតុភូមិនិវត្តន៍មកក្នុងប្រទេសវិញ" ។ អង្គការមានគម្រោងជាច្រើនដូចជា កម្មវិធីអប់រំ កម្មវិធីអភិវឌ្ឍជនបទ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ-ល- ។

អង្គការបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមួយ ក្នុងគោលបំណងបង្រៀនជំនាញ ដល់ជនពិការដើម្បីឱ្យពួកគេអាចយកជំនាញទាំងនោះ ទៅប្រកបរបរចិញ្ចឹមជីវិតដោយខ្លួនឯង ។ លោកហ៉ រ គី បានសង្កត់ធ្ងន់ទៀតថា: "ទោះបីជាបងប្អូនធ្លាក់ខ្លួនពិការក្តី បងប្អូនក៏ត្រូវខិតខំប្រឹងប្រែងតស៊ូក្នុងជីវិតនេះដោយផ្តល់តម្លៃ ដល់ជីវិតរបស់ខ្លួនឯងផ្ទាល់" ។ សព្វថ្ងៃនេះមជ្ឈមណ្ឌលបន្ទាយព្រាប មានបង្រៀនលើជំនាញ៥ : កសិកម្ម អេឡិចត្រូនិច ជាងម៉ាស៊ីន កាត់ដេរ និងជាងចម្លាក់ ដែលសិស្សត្រូវសិក្សារយៈពេលពីរឆ្នាំ ហើយអង្គការជាអ្នកឧបត្ថម្ភទាំងស្រុងក្នុងអំឡុងពេលសិក្សានេះ ។

ចំណែកលក្ខខណ្ឌសម្រាប់ជ្រើសរើស ឱ្យចូលមជ្ឈមណ្ឌលគឺសិស្សទាំងពីរភេទ ជាជនពិការជើង ដែលគ្រួសារមានស្ថានភាពក្រីក្រ ពិការរងគ្រោះ ដោយសារមីន គ្រោះថ្នាក់ចរាចរ ឬក៏ដោយសារជំងឺគ្រុនស្វិតដៃជើង ។ សិស្សគឺត្រូវមានអាយុចាប់ពី១៨ឆ្នាំដល់៣៥ឆ្នាំ ។ ហើយអង្គការក៏នឹងជ្រើសរើសសិស្សចាប់ពីពាក់កណ្តាលខែកក្កដានេះ រហូតដល់បំណាច់ឆ្នាំ២០០៨ ។ វគ្គសិក្សាថ្មីនឹងបើកបង្រៀននៅដើមឆ្នាំ២០០៩ខាងមុខនោះ ។

# សំ អុន : "យើងតស៊ូដើម្បីធ្វើឱ្យជីវិតយើងបានល្អប្រសើរ"

អង្គុយនៅលើរទេះ និងកំពុងពន្យល់សិស្សពិការពីរបៀបឆ្លាក់រូប លោកសំ អុន គឺជាគ្រូបង្ហាត់ចម្លាក់ប្រចាំមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការបន្ទាយព្រាបរបស់អង្គការជេអេសស៊ី ស្ថិតនៅស្រុកអង្គស្នួល ខេត្តកណ្តាល ។

ជាមួយនិងស្នាមញញឹម លោកមានប្រសាសន៍ថា: "លោកមានស្រុកកំណើតនៅខេត្តពោធិ៍សាត់ ។ រូបលោកធ្លាក់ខ្លួនពិការ ពេលលោកនៅធ្វើជាទាហានក្នុងខណៈដែលឡានលោកជិះទៅកាន់អង្គភាពនាខេត្តឧត្តរមានជ័យបានជាន់មីន ក៏បណ្តាលឱ្យលោករងរបួសធ្ងន់ធ្ងររហូតដល់ធ្លាក់ខ្លួនពិការជើងទាំងពីរចាប់ពីឆ្នាំ១៩៩៤ ។ ក្រោយពីជាសះពីរបួស លោកបានអង្គការជ្រើសរើសឱ្យចូលរៀនខាងចម្លាក់ និងក្លាយជាគ្រូផ្នែកចម្លាក់នេះចាប់ពីឆ្នាំ១៩៩៦មក" ។ ឆ្លងកាត់បទពិសោធន៍ការងារ និងការតស៊ូក្នុងជីវិតជាជនពិការ លោកក៏សុំផ្តាំផ្ញើដល់បងប្អូនពិការទាំងអស់ថា : "ជីវិតយើងម្នាក់ៗមានតម្លៃ ដូច្នេះយើងត្រូវចាប់យកជំនាញមួយឱ្យបានច្បាស់លាស់ មិនថាខាងចម្លាក់ អេឡិចត្រូនិច ជាងម៉ាស៊ីនទេ ឬជំនាញអ្វីផ្សេងទៀត ។ បើយើងចេះច្បាស់លាស់នូវជំនាញនេះ វាអាចជួយឱ្យយើងងាយស្រួល ក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ។ ទោះបីយើងពិការ លំបាកក្តី យើងត្រូវការតស៊ូឱ្យខ្លាំងជាងអ្នកដទៃទៀត ទើបធ្វើឱ្យជីវិតយើងបានល្អប្រសើរឡើងទៅមុខ" ។


Photo : L. Samphors

ក្រៅពីការងារជាគ្រូផ្នែកចម្លាក់ លោកសំ អុន មានទទួលឆ្លាក់រូបផ្សេងៗអំពីថ្ម ឬឈើ តាមតម្រូវការរបស់អតិថិជនផងដែរ ។ បើលោកអ្នកមានចំណាប់អារម្មណ៍ ក៏សូមទំនាក់ទំនងមកកាន់ទូរស័ព្ទលេខ : ០១២ ៦៣៩ ៦២៧ និង០១៦ ៤៩៨ ៥១៣ ។

June-2008.qxd 5/21/2008 11:12 AM Page 9





Photo : Anne-laure Porée

# ភាពស្មោះត្រង់យុវវ័យ : ប្រាកដភាព ឬវិទ្យាសាស្ត្រប្រឌិត

**អាន ឡូរ៉ី ប៉ូរ៉េ**

នៅក្នុងការិយាល័យ ដែលមានខ្យល់រំភើយៗដោយស្លាបកង្ហារ លីណា និងសុផនអស់សំណើច និងស្រដីឆ្លើយតបដោយខ្វែងគំនិតគ្នា :

-"ខ្ញុំ! ខ្ញុំជឿលើភាពស្មោះត្រង់ក្នុងចំណោមអ្នកក្រីក្រ" យុវជនវ័យក្មេងពន្យល់ "ប៉ុន្តែនៅពេលដែលមនុស្សក្លាយជាអ្នកមាន ពួកគេក៏ងាយស្រួលនឹងធ្វើឱ្យនារីវ័យក្មេង និងស្អាតៗស្រឡាញ់" ដោយហេតុថាគឺលុយដែលធ្វើឱ្យនារីចាប់អារម្មណ៍។

-នៅពេលយើងសួរថា "តើអ្នកឯងទុទិដ្ឋិនិយមឬ?" លីដាបានឆ្លើយតបទៅកាន់យុវជននោះភ្លាមៗ និងដោយស្រងាកចិត្តបន្តិចថា : "ស្ត្រីគ្រប់ៗរូបមិនសុទ្ធតែស្វែងរកលុយទាំងអស់នោះទេ។ នៅមានស្ត្រីខ្លះកំពុងស្វែងរកស្នេហាពិតផងដែរ!"

គំនិតខ្វែងគ្នានេះ គឺគ្រាន់តែរំលេចឱ្យឃើញនូវភាពឃ្លាតឆ្ងាយពីគ្នារវាងបុរស និងស្ត្រីទៅលើទស្សន-ទាននៃភាពស្មោះត្រង់ក្នុងសេចក្តីស្នេហា ដែលស្ត្រីហាក់បីដូចជាត្រូវបានលើកតម្លៃប្រសើរជាង។ តើបុរសមានភាពស្មោះត្រង់ដែរឬទេ? ចម្លើយគឺទេ! ស្ត្រីខ្មែរវ័យក្មេងជារឿយៗ ឆ្លើយយ៉ាងនេះ មុននឹងបង្ហាញគំនិតផ្សេងពីនេះបន្តិចដែរថា នេះអាស្រ័យលើចរិតរបស់មនុស្សម្នាក់ៗ។

ផានិត អាយុ ២៣ឆ្នាំ។ នាងទើបនឹងបានរៀបការរួចប៉ុន្មានខែ។ ដោយពុំភ័យបារម្ភថា ស្វាមីក្បត់ចិត្ត នាងបានប្រាប់ថា: "ប្រសិនបើជាបុរសមិនមានភាពស្មោះត្រង់ ស្ត្រីត្រូវសួរខ្លួនឯងថាហេតុអ្វី? ប្រហែលជានាងមិនចេះគ្រប់គ្រង(ថែទាំ)ផ្ទះឱ្យបានល្អ" នៅគ្រប់ករណីទាំងអស់ ប្រហែលមកតែពីស្ត្រីដែលជាមូលហេតុនៃការបែកបាក់។ ចំណែកធម្មជាតិរបស់បុរសគឺដូច្នោះឯង(ចាំសម្គាល់មើល!)"។

យុវនារីវ័យក្មេង ដែលមានអារម្មណ៍រីករាយ រតនាបញ្ជាក់ថា នាងបានរាប់ភ្លេចនូវចំនួនបុរសដែលបានសារភាព រឿងគេមិនស្មោះត្រង់នេះ។ វិលមកកាន់ផានិតវិញយល់ថា សម្រែកកំហឹង និងការប្រច័ណ្ឌគឺមិនត្រូវប្រើទេ។ "ការបញ្ចេញកំហឹង និងការខឹងសម្បារគ្មានបានផលអ្វី ក្រៅពីធ្វើឱ្យប្តីកាន់តែឃ្លាតឆ្ងាយ។ ខ្ញុំគ្មានសិទ្ធិនឹងហាមឃាត់គាត់ មិនឱ្យក្បត់ចិត្តទេ។ នេះគឺជារឿងធម្មតា។ ប្រសិនបើរឿងនេះកើតឡើងចំពោះខ្ញុំ ខ្ញុំនឹងនិយាយទៅគាត់ដោយទន់ភ្លន់ និងសាកសួរគាត់ដើម្បីយល់អំពីបញ្ហា"។ ប៉ុន្តែលីដានៅទាល់គំនិតអំពីរឿងនេះ។ ចំណែកឯផានិតក៏បានសង្កត់ធ្ងន់ទៀតថា: "ស្ត្រីដែលលះលែងស្វាមីហើយ នឹងមិនរកបានស្វាមីទី២ទៀតបានឡើយនៅប្រទេសខ្មែរ គឺវៀរលែងតែនាងមានការអប់រំល្អ"។ ចំណែកលីដាកំពុងសួររកមូលហេតុ ដែលនាំឱ្យស្ត្រីខ្មែរត្រូវលះបង់ច្រើន។ "ខ្ញុំជឿថានេះមកពីវប្បធម៌របស់យើង។ តាំងតែពីយើងនៅតូច គេបានបណ្តុះគំនិតយើងអំពីច្បាប់ស្រី។ គេបានប្រាប់យើងថា គួរប្រព្រឹត្តអាកប្បកិរិយាមាយាទយ៉ាងម៉េច។ ចំណែកក្មេងប្រុសមានសំពាធតិចជាង។ បុរសពុំស្មោះត្រង់គឺអាចទទួលយកបានបើស្រីមិនអាចទេ"។ មិត្តភ័ក្តភេទប្រុសរបស់ពួកគេបានយល់ស្របតាមនេះ និងការពិភាក្សា ក៏ងាកចេញយ៉ាងរហ័សពីនេះទៅកាន់រឿងយុវសិស្សនារីវិទ្យាល័យក្មេងៗខ្លះ ដែលអាចងាយប្រឈមរួមភេទជាមួយសិស្សប្រុសដែលទើបនឹងទិញម៉ូតូទាន់សម័យសេរីចុងក្រោយប្រើ។

សារិទ្ធ អាយុ២៩ឆ្នាំ ទើបតែរៀបការជាមួយមករា អាយុ២៣ឆ្នាំ។ មុននឹងសម្រេចចិត្តរៀបការ ភរិយាគាត់បានសួរពីផែនការអនាគតគ្រួសារ។ គាត់ត្រូវសរសេរដោយផ្ទាល់ដៃ។ គាត់បានស្នើចែកចេញជាបីចំនុច គឺទី១ *លុយ ទី២ ទំនាក់ទំនងស្វាមី ភរិយា និងគ្រួសារ និងទី៣ អំពីអនាគត*។ នៅក្នុងកម្មវិធីនេះ គាត់មិនបានជជែកដោយផ្ទាល់អំពីរឿងស្មោះត្រង់ទេ ប៉ុន្តែភរិយាគាត់ជឿថា ទស្សនទានគ្រួសារមានមូលដ្ឋានគ្រឹះ លើការគោរពគ្នាទៅវិញទៅមករវាងស្វាមី និងភរិយា។ ប៉ុន្តែមានរឿងមួយនៅក្នុងខួរក្បាលរបស់គាត់ គឺភាពមិនប្រាកដប្រជា: "ទោះបីខ្ញុំ និងនាងប្រាប់គ្នាថា ស្មោះត្រង់។ ប៉ុន្តែជីវិតនៅវែងឆ្ងាយ ចំណែកមនោសញ្ចេតនាអាចប្រែប្រួល។ យើងមិនដឹងសោះអំពីអនាគត តែយើងជ្រើសរើសរស់នៅជាមួយគ្នាលើមាគ៌ានៃភាពស្មោះត្រង់"។

## បទយកការណ៍

# តើយុវវ័យធ្វើអ្វីជាការកំសាន្តនៅពេល ពួ

**អាន ឡូរ៍ ប៉ូរ៉េ**

នៅពេលដែលអ្នកសម្ភាសន៍យុវជនចំពោះអ្វីដែលគេធ្វើនៅពេលទំនេរ ពួកគេតែងនៅទ្រឹងមួយភ្លែត ដោយហេតុថា នៅក្នុងសង្គមកម្ពុជាដែលកំពុងតែអភិវឌ្ឍន៍រីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃនេះ ពួកគេមានទំនោរទៅរកការពិភាក្សាពីការងារជាមុន មុននឹងជជែកអំពីការកំសាន្ត។ ប៉ុន្តែការជជែកអំពីប្រធានបទនៃការកំសាន្តនេះធ្វើឱ្យលេចឡើងនូវរឿងរ៉ាវដែលគួរឱ្យកត់សម្គាល់មួយចំនួនផងដែរ : យុវជន គឺតែងតែអផ្សុកម្តងម្កាលជាធម្មតា។ ប៉ុន្តែចំពោះពួកគេ មិនមានអ្វីចោទជាបញ្ហាធំនោះទេ។ ពួកគេមិនដែលធ្វើអ្វីដែលទៅមិនរួចនោះឡើយ។ តាមរបៀបជាទូទៅចំណង់របស់ពួកគេ ត្រូវគ្នានឹងអ្វីដែលពួកគេអាចធ្វើបាន អាចចូលទៅដល់ និងមិនមានការទាមទារអ្វីជាលក្ខណៈពិសេសពេកទេ។

**ចំណាយពេលច្រើនជាងគេ : គឺមើលទូរទស្សន៍**

មិនមាននរណាដែលមិនមើលទូរទស្សន៍ឡើយ នៅពេលដែលគេមានពេលទំនេរ និងខ្ជិលចេញទៅដើរលេងខាងក្រៅ! ចម្រៀងកាយវិការខារ៉ាអូខេ បានទទួលជោគជ័យយ៉ាងខ្លាំងសម្រាប់ចក្ខុ ដែលគ្មានអ្វីគួរឱ្យឆ្ងល់ច្រើនពេកទេនាពេលសព្វថ្ងៃនេះ។ សិលា អាយុ២៥ឆ្នាំ មានចំណង់ចំណូលចិត្តមើលនូវកម្មវិធីសិល្បៈទស្សនីយភាព និងរបាំប្រពៃណីជាដើម ។រីងលីណា អាយុ១៩ឆ្នាំ បានជក់ចិត្តមើលរឿងភាគចិនដោយមិនដាក់ភ្នែកជារៀងរាល់ថ្ងៃ។ ប្រសិនគ្រាន់តែមើលប៉ុស្តិ៍ទូរទស្សន៍ទាំង៧ របស់កម្ពុជា កម្មវិធីពុំមានកម្មវិធីអ្វីប្លែកៗច្រើនទេ។ បើតាមប្រសាសន៍លោកអូលីវីយេ ស៊ីប៊ែរ ជានាយកប្រតិបត្តិទូរទស្សន៍អប្សរា បានបង្ហាញឱ្យដឹងថា ខ្លឹមសារកម្មវិធី មានបញ្ហាចោទឡើង និងនៅតែបន្តចោទឡើងជាដរាបដោយសារតែកង្វះខាតនៃធនធានមនុស្សដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីផលិតកម្មវិធីប្រកបដោយគុណភាព។ ទោះជាយ៉ាងណានៅប្រទេសកម្ពុជា មានប៉ុស្តិ៍ទូរទស្សន៍បរទេសជាច្រើនទៀត ដែលយើងអាចមើលបានតាមរយៈទូរទស្សន៍ខ្សែកាប។ ហើយសព្វថ្ងៃនេះ មានប៉ុស្តិ៍ផ្សាយតាមផ្កាយរណបផងដែរ។ ប៉ុន្តែប៉ុស្តិ៍ទូរទស្សន៍ទាំងនេះ សម្រាប់អ្នកដែលមានលទ្ធភាពបង់ថ្លៃសេវាកម្មឱ្យក្រុមហ៊ុនតែប៉ុណ្ណោះ។



Photo : L. Samphors

## មិនមានភាពស្មើគ្នានៅពីមុខការកំសាន្ត

**មនុស្សម្នាក់ៗមានការលេងកំសាន្តជាមួយនិងពេលវេលាផ្ទាល់ខ្លួន។ ហើយការកំសាន្តរបស់ពួកគេក៏អាស្រ័យទៅតាមស្ថានភាពគ្រួសារ និងសង្គមរបស់ពួកគេផងដែរ។**

**នៅសាលា Happy Chandara ដែលមានទីតាំងស្ថិតនៅប្រមាណជា៥០គម ពីទីក្រុងភ្នំពេញ ក្មេងស្រីតូចៗ ដែលមានប្រភពពីគ្រួសារក្រីក្របំផុតនៅក្នុងភូមិ មិនដែលចេះលេងកំសាន្តទេ និងក៏មិនមានឱកាសនឹងលេងកំសាន្តដែរ នៅពេលពួកនាងទៅសាលារៀន។ គ្រូៗនៅក្នុងសាលារៀបរាប់ថា ពួកនាងមិនដឹងចេះលេងបាល់បាឡុងយ៉ាងម៉េចទេ។ ប៉ុន្តែពួកនាងបានបេះ និងរំលស់លក់ផ្កាម្លិះនៅសាលារៀនដើម្បីរកប្រាក់ចំណូលបន្ថែមដើម្បីបន្ធូរបន្ថយការលំបាករបស់មនុស្សមួយផ្ទះរបស់ពួកនាងដែលសង្ឃឹមលើរបរតិចតួចនេះ។**

**ចេញដើរលេងខាងក្រៅជាមួយមិត្តភក្តិ**

នៅក្នុងចំណោមការចេញកំសាន្ត ក៏មានសកម្មភាពដែលយុវជនវាយតម្លៃថា ចូលចិត្តបំផុត។ តួយ៉ាងការប្រមូលគ្នាជាក្រុមដើម្បីទៅមើលខ្សែភាពយន្ត ឬមួយទៅក្លឹបរាត្រីដើម្បីស៊ីផឹកជាមួយគ្នា។យុវជនសិលាអះអាងថា: "ខ្ញុំពុំដែលគិតចេញទៅខាងក្រៅម្នាក់ឯងទេ។កាលខ្ញុំនៅជានិស្សិតរៀននៅសកលវិទ្យាល័យ ខ្ញុំក៏ធ្លាប់ចេញទៅលេងខាងក្រៅជាមួយមិត្តភក្តិខ្ញុំជាញឹកញាប់ ទោះបីយើងមិនមានលុយក៏ដោយ។ ប៉ុន្តែឥលូវខ្ញុំធ្វើការខ្ញុំមានប្រាក់ខែ បែរជាគ្មានពេលនឹងចេញដើរលេងទៅវិញ។ អ៊ីចឹងហើយនៅពេលដែលខ្ញុំមានសម្រាកវិស្សមកាល ខ្ញុំក៏ស្វែងរកមិត្តភក្តិរបស់ខ្ញុំ ហើយនៅសៀមរាប យើងចេញទៅក្លឹបរាត្រីជាមួយគ្នា។ រង្គសាល "Zone 1" គឺជាកន្លែងណាត់ជួបដែលយើងចូលចិត្តជាងគេ វាថ្មី និងទាន់សម័យបំផុត និងមានរង្គសាល X.O ផងដែរ។ ប៉ុន្តែ "Le Martini" យើងទៅតិចតួចទេ គឺវាដូចជាហួសសម័យហើយសព្វថ្ងៃ"។ ចំណែកនៅឯភ្នំពេញ

# ល ពួកគេទំនេរ?



មជ្ឈមណ្ឌល **Spark** ហើយនិងអ្នកចម្រៀងទីនោះនៅតែពេញនិយម និងក៏មិនសូវថ្លៃដូចមជ្ឈមណ្ឌលទើបបើកទំនើបថ្មី **Rock** ទេ។

កំពុងអង្គុយនៅលើកៅអី ពីមុខបណ្ណាល័យសោតទស្សន៍នៃមជ្ឈមណ្ឌលវប្បធម៌បារាំង ក្រុមនិស្សិតទាំងអស់ អាយុស្របាល២០ឆ្នាំ បានរៀបរាប់យ៉ាងអៀនប្រៀនថា ជួនកាលពួកគេក៏ចូលចិត្តទៅលេងព្រែកលាបនៅចុងសប្តាហ៍ ពួកគេចាកចេញពីក្រុងពេលថ្ងៃបន្តិចនៅតាមផ្លូវទៅកាន់សៀមរាប ហើយសម្រាកហូបបាយថ្ងៃត្រង់ នៅតាមមាត់ទឹក ពួកគេសម្រាកគេងយោលអង្រឹង អ្នកខ្លះអង្គុយលេងបៀកំសាន្តយ៉ាងយូរពេញមួយថ្ងៃ។ ឯអ្នកខ្លះទៀតការណាត់ជួបត្រូវកំណត់ធ្វើនៅក្នុងភោជនីយដ្ឋានណាមួយដោយក្តីរីករាយនៅជុំវិញឆ្នាំងដ៏ធំមួយ។

ចេញដើរជាមួយមិត្តភ័ក្តិមិនសុទ្ធតែត្រូវឱ្យចំណាយទាំងអស់ទេ។តើមានយុវជនប៉ុន្មាននាក់ ដែលដើរកំសាន្តសប្បាយៗ នៅតាមមាត់ទន្លេទីក្រុងភ្នំពេញ ឬអង្គុយលេងលើបង់នាសួនច្បារសម្តេចហ៊ុន សែន "ដើម្បីមើលគេមើលឯង" "ដើម្បីមើលអ្វីដែលថ្មី" "ដើម្បីមើលមនុស្សម្នា" និង"ដើម្បីមើលស្រីស្អាត" ក្នុងនោះមាន តឿ អាយុ២៣ឆ្នាំ ដែលកំពុងអង្គុយលេងនៅមាត់ទន្លេផងដែរ លោកជាអ្នករត់ម៉ូតូឌុប អាយុ២៣ឆ្នាំ លោកមកសម្រាកលេងដើម្បីបំភ្លេចនូវការលំបាកក្នុងជីវភាពប្រចាំថ្ងៃ។ លោកនិយាយថា: "ខ្ញុំស្រឡាញ់ភ្នំពេញ ពីព្រោះគេអាចដើរលេងកំសាន្តបាន"។ ផ្ទុយទៅវិញ វ៉េវ ដែលជាយុវកម្មករ អាយុ២០ឆ្នាំ ដែលបានមកពីស្រុកកៀនស្វាយ ខេត្តកណ្តាល មិនចង់នៅភ្នំពេញនោះទេ។

**ដើរទិញឥវ៉ាន់**

កញ្ញា អ្នកងប់ងល់នឹងម៉ូតថ្មីៗយ៉ាងខ្លាំងក្លា ទទួលស្គាល់ថា ទម្លាប់អាក្រក់របស់នាងគឺនៅចុងសប្តាហ៍មានរាប់បញ្ចូលការដើរទៅមក នៅជាន់នៃមណ្ឌលផ្សារសូរិយា ដូចជាដើម្បីស្វែងទិញអាវយឺតរូបបេះដូងដែលមិត្តស្រីចង់ឱ្យនាងពាក់។ នាងមានចំណាប់អារម្មណ៍នឹងទូរស័ព្ទដែលចេញម៉ូដែលចុងក្រោយបំផុត ជួនកាលនាងត្រូវចំណាយប្រាក់អស់មួយខែដើម្បីទិញវា! ម្យ៉ាងទៀតថ្ងៃដែលល្អ សម្រាប់នាងគឺនាងអាចញ៉ាំនំភីហ្សា នៅឯ **Pizza Company**។ នាងចូលចិត្តញ៉ាំអាហារសម្រន់ពោះដូចជាផ្លែសឺរីសសាច់ក្រក់ខ្លាញ់ជ្រូក លើនំភីហ្សា ព្រមជាមួយនិងមីអ៊ីតាលីជាដើម (ទោះបីអាហារទាំងនេះមិនមានរសជាតិដូចនៅប្រទេសដើមរបស់វាក៏ដោយ)។

**កីឡា និងការលេងនៅកណ្តាលវាល**

ប្រសិនជាជនជាតិខ្មែរខ្លះ ច្រើនមានចំណូលចិត្តនឹងភាពទាន់សម័យនៃនំភីហ្សា អ្នកខ្លះគឺពេញចិត្តពិតប្រាកដនឹងការលេងកីឡា។ បាល់ទាត់ បាល់ទះ និងសី ជាអ្វីដែលជាចំនូលចិត្តរបស់ប្រជាជនខ្មែរ។ នេះគឺច្បាស់ណាស់ គេលេងពាសពេញប្រទេស។ កីឡាប៉េតង់(បោះប៊ូល)ផងដែរ គ្រាន់តែធ្វើឱ្យគេនឿយហត់បន្តិច។ ហើយសម្រាប់ស្ត្រីគឺកីឡា បែតមីនតុនដែលពួកគេចូលចិត្តលេងនៅពេលថ្ងៃលិច។ ហើយជាញឹកញាប់ មានកីឡាលេងវាយប៉េងប៉ុងផងដែរ ទោះបីការលេងវា ត្រូវចំណាយថ្លៃ ពីព្រោះគេត្រូវជួលតុតាមម៉ោង។ សុភាពអាយុ ១២ឆ្នាំ ធ្លាប់បានលេង ក្នុងថ្នាក់រៀនជាមួយមិត្តភ័ក្តិរបស់នាង ដែលចូលចិត្តល្បែងកំសាន្តប្រជាប្រិយ។ ផ្ទុយទៅវិញ សូធិក ជាបុរសដែលប្រកបដោយកម្លាំងខ្លាំងក្លាអាយុ ៤០ឆ្នាំ បានយកចិត្តទុកដាក់ និងទម្លាប់ឱ្យកូនរបស់លោកលេងកីឡា។ នៅក្រុងភ្នំពេញ គាត់នាំពួកគេទៅកាន់ស្តាតអូឡាំពិក ដើម្បីបង្វឹកពួកគេជិះកង់ជារៀងរាល់ចុងសប្តាហ៍។

**ល្បែងវីដេអូ (ហ្គេម)**

ការលេងហ្គេមជាទូទៅត្រូវបានគេគិតថា មិនត្រឹមត្រូវនោះទេ។ ប៉ុន្តែក្មេងៗទទួលការចាប់អារម្មណ៍នឹងការលេងហ្គេមនេះមានកាន់តែច្រើនឡើងៗ។ ហើយកន្លែងបើកអាជីវកម្មល្បែងហ្គេមនេះពុំមានការថយចុះទេ និងរីកដុះដាលគ្រប់ទីកន្លែង។ កុមារពុទ្ធី អាយុ១៥ឆ្នាំ បានចំណាយពេលវេលាច្រើនក្នុងការលេងហ្គេម **Play Station 2** ហើយនៅពេលដែលគេឃើញពូរបស់គេមកលេងផ្ទះ គេបានឆ្លៀតឱកាសសុំឱ្យពូទៅទិញហ្គេមថ្មីសម្រាប់ឱ្យគេ។

**ការអាន និងការលេងរៀនសូត្រ**

រឿងនេះមិនរារាំងចំពោះក្មេងដែលចង់ចេះ ចង់ដឹង និងស្តាប់បង្គាប់មិនឱ្យស្រឡាញ់អំនានឡើយ។ តែអំនានក៏គេអាចកំណត់ថា ជាការកំសាន្តមួយដែរ។ គ្រាន់តែវាមិនត្រូវបានចាត់ទុកថា ជាសកម្មភាពនាពេលសម្រាក។ ទោះជាយ៉ាងណា នាថ អាយុ ១០ ឆ្នាំ សប្បាយចិត្តជាខ្លាំងនឹងនិទាននូវរឿងប្រវត្តិតាត្រសក់ផ្អែមឱ្យបងស្រីរបស់ខ្លួនស្តាប់។ ស្រីនិច ផងដែរ អាយុ ១៣ឆ្នាំ តែងតែចំណាយពេលនៅពេលចេញលេងម៉ោងទីពីរដើម្បីអានសៀវភៅ!

នៅក្បែរនោះ យុវជនវណ្ណាប្ញទ្ធិ អាយុ ២០ឆ្នាំ បានសម្រេចក្នុងចិត្តថា សារៈសំខាន់គឺការរៀនសូត្រ ជាជាងការកំសាន្តសប្បាយ។ អ៊ីចឹង គាត់បានចំណាយម៉ោងទំនេរដើម្បីសិក្សាភាសាអង់គ្លេស!។

## ការកំសាន្តគឺល្អដើម្បីការរីកលូតលាស់ប្រកបដោយគុណភាព

**ការកំសាន្តគឺមានសារៈសំខាន់ណាស់នៅក្នុងជីវិតរស់នៅ ដោយសារវាបានអភិវឌ្ឍនូវសមត្ថភាពទាំងផ្លូវចិត្ត និងរាងកាយរបស់មនុស្ស ជាពិសេសយុវជន ព្រមទាំងបង្កើននូវចំណេះដឹង និងគំនិតបង្កើតថ្មីផងដែរ។ ការកំសាន្ត ដែលយើងរាប់ឃើញល្បែងកំសាន្ត កីឡា ទស្សនីយភាព ការសម្តែងសកម្មភាពវប្បធម៌ ក៏ដូចជាការដែលយើងធ្វើការងារដែលមានប្រយោជន៍ និងជាចំណង់ចំនូលចិត្តរបស់យើងជាទូទៅផងដែរ។ យោងទៅតាមសកម្មភាពទាំងនេះ បងស្រីលីណា ដែលធ្លាប់ចូលរួមយុទ្ធនាការកាកបាទក្រហមក្នុងនាមស្ម័គ្រចិត្តបានឱ្យដឹងថា សកម្មភាពទាំងនេះអនុញ្ញាតឱ្យមនុស្សអាចធ្វើសមាហរ័ណកម្មដ៏ប្រសើរជាមួយគ្នាមួយនៅក្នុងសង្គម ឱ្យពួកគេមានភាពជឿជាក់លើខ្លួនឯង និងជាគន្លឹះនៃភាពសប្បាយរីករាយដ៏ពិតប្រាកដមួយនៅក្នុងជីវិតរស់នៅក្នុងសង្គម។**

June-2008.qxd 5/21/2008 11:13 AM Page 12



# រដូវវស្សា : គួរជ្រើសរើសពូជស្រូវ

**ផាត សំភី**



Photo : L. Samphors

តាមប្រសាសន៍លោកគាម មករាឌី អ្នកស្រាវជ្រាវបច្ចេកទេសនៃអង្គការសេដាក បានឱ្យដឹងថា: ពូជស្រូវចែកមានបីប្រភេទ គឺពូជស្រូវស្រាល ស្រូវកណ្តាល និងស្រូវធ្ងន់។ ស្រូវស្រាលមានដូចជា ពូក IR ដែលរយៈពេលឱ្យផលរបស់វា គឺ១១០ថ្ងៃចុះ។ ស្រូវកណ្តាល មានដូចជាស្រូវ ផ្កាខ្ញី ផ្កាម្លិះ ផ្ការំដួល សែនពិដោរនិងIR66-ល- ហើយរយៈឱ្យផលរបស់វាគឺក្នុងរង្វង់៤ខែ។ ចំណែកស្រូវធ្ងន់ មានច្រើនពូជដែរ ដូចជានាងលក្ខណ៏ ធ្លាក់សន្ទឹក នាងពួនបីគួរ... ដែលកសិករអាចប្រមូលផលក្នុងអំឡុងលើសពី៥ខែ ឬរហូតដល់៧ខែ។

ការធ្វើស្រូវឱ្យបានទិន្នផលខ្ពស់ វាអាស្រ័យលើស្ថានភាពដីប្រើជី ធ្វើដីឱ្យបានធូរនិងគ្រប់គ្រងទឹកឱ្យបានដិតដល់។ តាមបទពិសោធន៏កន្លងមក ស្រូវស្រាល ឬកណ្តាល កសិករអាចដាំនៅលើដីនៅជុំវិញភូមិ ឬដីខ្ពស់បាន។ ចំណែកស្រូវធ្ងន់ កសិករនិយមដាំនៅលើដីថ្លុកបាតបឹង ឬបាតត្រពាំង។

តែទោះជាយ៉ាងណាក៏ដោយ ដោយសារសព្វថ្ងៃនេះកត្តាអាកាសធាតុប្រែប្រួល ភ្លៀងធ្លាក់ពុំទៀងទាត់ កសិករគួរតែជ្រើសរើសដាំពូជស្រូវស្រាល និងស្រូវកណ្តាល ព្រោះវាប្រឈមតិចតួចទៅនឹងគ្រោះរាំងស្ងួត។ ស្រូវធ្ងន់តាមធម្មតាគឺផ្តល់ទិន្នផលខ្ពស់ជាងស្រូវស្រាល និងស្រូវកណ្តាល ប៉ុន្តែវាអាចស្កកនៅចុងរដូវដោយសារខ្វះទឹក ដែលធ្វើឱ្យខូចទិន្នផល។ តាមពិតទោះបីកសិករធ្វើស្រូវកណ្តាលក៏ដោយ តែបើគាត់អនុវត្តតាមបច្ចេកទេស និងប្រពលវប្បកម្មដំណាំស្រូវឱ្យបានត្រឹមត្រូវទិន្នផល វាអាចខ្ពស់ជាងការធ្វើស្រូវធ្ងន់ផង។

លោកគាម មករាឌី បានធ្វើការផ្តាំផ្ញើថា រដូវវស្សាចូលមកដល់ កសិករគួរត្រៀមពូជស្រូវឱ្យបានល្អ។ បើមិនមានពូជស្រូវ កសិករត្រូវសួររកពូជពីអ្នកជិតខាង ប៉ុន្តែត្រូវតែជាពូជសម្រិតសម្រាំងឱ្យបានសុទ្ធល្អ។ កសិករគួរជ្រើសរើសពូជសុទ្ធ ដែលអាចផ្តល់ទិន្នផលខ្ពស់។ ការសម្រាំងពូជ គឺត្រូវសង្កេតមើលក្នុងស្រែតាំងពីវគ្គលូតលាស់ រហូតដល់ចេញផ្កា ផ្លែ និងជ្រើសយកគ្រាប់ស្រូវដែលចេញអំពីគួរដំណាលគ្នា។ កសិករអាចស្វែងរកនូវពូជពីអង្គការឬស្ថាប័ននានា។ ចំនុចមួយទៀត ការធ្វើជីទ្រាប់បាតកសិករអាចព្រោះស្នោរ ឬសណ្តែកចុងខែ៤ ឬខែ៥ ដល់ខែ៦ ឬខែ៧ កសិករអាចភ្ជួរលប់ ហើយស្ទូង។ កសិករគួរត្រៀមជីធម្មជាតិដូចជាលាមកសត្វកាកសំណល់ផ្សេងៗ ដើម្បីធ្វើជាជីកំប៉ុស្តដាក់ស្រែផងដែរ។

បរិស្ថាន

## ផែនដីកើនកម្តៅ

បញ្ហាសព្វថ្ងៃគឺជាកំណើនសីតុណ្ហភាព នៅក្នុងបរិយាកាស និងនៅលើផែនដី។ ការកើនកម្តៅនេះគឺបណ្តាលមកពីមូលហេតុធំៗពីរចំណុច : ទីមួយ គឺកំណើនការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅលើបរិយាកាស និងការបាត់បង់ព្រៃឈើ។



Photo: DR

ឧស្ម័នផ្ទះកញ្ចក់កំណត់ដោយពិធីសារក្យូតូនៅជប៉ុនដែលអនុម័តនាខែធ្នូ ឆ្នាំ១៩៩៧ មាន ៦ប្រភេទ គឺឧស្ម័នកាបូនិក មេតាន អាម៉ូញាក់ ស៊ុលផួភ្លួរិលកាបូន ផឺភ្លួរិលកាបូន និងស៊ុលផួហិចសាភ្លួរ៉ែ។

កំណើននៃឧស្ម័នទាំងនេះ ហុចជាផលនៃផ្ទះកញ្ចក់ គឺពេលដែលឧស្ម័នទាំងនេះមានក្នុងបរិយាកាសច្រើនពួកវានឹងចាប់យកកំដៅកាំរស្មីពីព្រះអាទិត្យដែលធម្មតាត្រូវភាយពីផែនដីទៅលំហវិញ។ នេះធ្វើឱ្យផែនដីឡើងក្តៅធំ។ ដូច្នេះកាលណា កំហាប់ឧស្ម័នទាំងនេះកើនច្រើន ផែនដីកាន់តែកើនកម្តៅដែរ។ ឧស្ម័នផ្ទះកញ្ចក់ដែលសំខាន់ជាងគេ គឺឧស្ម័នកាបូនិក ដែលការបំភាយវាគឺច្រើនបណ្តាលមកពីសកម្មភាពរបស់មនុស្ស។ វាភាយចេញពីសំណល់កសិកម្ម សំរាម ដំណើរការឧស្សាហកម្ម សកម្មភាព ចំអិនអាហារ និងការប្រើប្រាស់ចរន្តអគ្គីសនីដែលមានប្រភពពីម៉ាស៊ីនដើរដោយប្រេង-ល-។ ចំណែកការបាត់បង់ព្រៃឈើ នាំឱ្យផែនដីបាត់បង់សមត្ថភាពស្រូបទាញឧស្ម័នកាបូនិក ដែលនាំឱ្យវាលើសពីកម្រិតធម្មជាតិ។

ជាសរុបកំណើននៃសីតុណ្ហភាពនៅលើផែនដីធ្វើឱ្យកើនកម្ពស់ទឹកសមុទ្រ និងកម្រិតទឹកភ្លៀង មិនទៀងទាត់ ដែលនេះប៉ះពាល់យ៉ាងខ្លាំងក្លាដល់ជីវចម្រុះលើផែនដី និងជីវិតរស់នៅរបស់ប្រជាជន។

**ផាត សំភី**

## សុខភាព

# គេងមិនលក់ជារោគសញ្ញាជំងឺផ្លូវចិត្ត និងផ្លូវកាយ

**ខាន់ ភីរម្យ**

ការគេងមិនលក់ជាប្រចាំ គឺមិនមែនជារឿងធម្មតានោះទេ។ ចំណែកឯបុគ្គលដែលជួបប្រទះបញ្ហានេះ សូមប្រញាប់ប្រញាល់មកជួបជាមួយនិងវេជ្ជបណ្ឌិតឯកទេសដើម្បីទទួលការព្យាបាល។

លោកស្រីចក ធីតា ជាអ្នកឯកទេសផ្នែកវិកលវិទ្យានៃគ្លីនិកធីតាគន្ធា បានអះអាងថា ការគេងមិនលក់ជាប់ៗគ្នាជាប្រចាំក្នុងមួយសប្តាហ៍ លើសពី៣ ទៅ៤ថ្ងៃ គួរតែទៅពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតឬក៏អ្នកឯកទេសឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងកុំឱ្យមានបញ្ហាប៉ះពាល់ដល់សុខភាព។ គេងមិនលក់តែងតែកើតមានចំពោះមនុស្សគ្រប់ៗគ្នា ប៉ុន្តែប្រសិនអ្នកគេងមិនលក់ជាប់ៗគ្នា ជាច្រើនថ្ងៃនោះ វានឹងធ្វើឱ្យអ្នកជំងឺនោះ ចុះខ្សោយគ្មានកម្លាំង វិលមុខ ឈឺក្រពះ ឈឺចាប់ពេញទាំងខ្លួន ឈឺក្បាល តឹងណែនសាច់ដុំ រោយក ស្រវាំងភ្នែក ហើយនិងរោគសញ្ញាសម្រាប់អាកប្បកិរិយា ដូចជាការធ្វើការមិនពេញលេញ និងរាងកាយទ្រុឌទ្រោមជាដើម។

លោកស្រី ក៏បញ្ជាក់ថា : "ការគេងមិនលក់ជារោគសញ្ញានៃជំងឺផ្លូវចិត្ត និងផ្លូវកាយ"។ លោកស្រីបន្តថា តាមប្រក្រតីមនុស្សពេញវ័យគួរគេងឱ្យបានពី៦ទៅ៧ម៉ោង ហើយចំពោះកុមារ ត្រូវគេងពី៨ ទៅ១០ម៉ោង ទើបមិនមានផលប៉ះពាល់សុខភាព។

លោកស្រីបានបញ្ជាក់ដែរថា ការគេងមិនលក់ អាចមកពីជំងឺផ្លូវកាយមួយចំនួន ជាពិសេស ភាគច្រើនវាអាចបណ្តាលមកអំពីបញ្ហាផ្លូវចិត្ត ដែលយើងគិតច្រើនពេក និងរកផ្លូវដោះស្រាយមិនចេញ។

លោកស្រីបានបន្តទៀតថា ដើម្បីដោះស្រាយបញ្ហានេះ អ្នកដែលជួបប្រទះបញ្ហាគេងមិនលក់នេះ គួរកុំទៅទិញថ្នាំងងុយគេងមកប្រើប្រាស់ដោយខ្លួនឯងពីព្រោះអាចនឹងធ្វើឱ្យយើងញៀន ហើយនិងធ្វើឱ្យពិបាកព្យាបាលនៅពេលក្រោយ។ វិធីព្យាបាលការគេងមិនលក់នេះ មានច្រើនយ៉ាងដូចជាវិធីព្យាបាលផ្តល់ប្រឹក្សា វិធីព្យាបាលដោយការនិយាយ ហើយនិងព្យាបាលដោយប្រើថ្នាំជាដើម-ល-។



Photo : S. Philong

បើយោងទៅតាមការអះអាងរបស់លោកស្រី ចក ធីតា បានឱ្យដឹងថា រហូតមកដល់ពេលនេះ នៅក្នុងចំណោមអ្នកជំងឺដែលមកកាន់ផ្នែកសុខភាពផ្លូវចិត្តនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ប្រមាណជាង២០០នាក់ជារៀងរាល់ថ្ងៃនោះ គឺមានអ្នកជំងឺចំនួនប្រមាណជា៩០ភាគរយ ដែលបានជួបប្រទះជាមួយនឹងបញ្ហានៃការគេងមិនលក់នេះ។

## កុមារចិន ៣៤នាក់ ស្លាប់ដោយវីរុសចម្លែក

**បើតាមភ្នាក់ងារព័ត៌មានចិន ស៊ីនហួរ បានឱ្យដឹងកាលពីថ្ងៃទី១១ ឧសភា ថា ជំងឺមាត់ជើងដៃបណ្តាលមកពីមេរោគ EV-71 បានសម្លាប់ជីវិតកុមារចិនយ៉ាងហោចណាស់ចំនួន៣៤នាក់។ ហើយជំងឺនេះកំពុងតែរីករាលដាលខ្លាំងក្នុងខេត្តក្វាងទុង និងខេត្តក្វាងស៊ី។ បើតាមអាជ្ញាធរចិនក្នុងឆ្នាំ២០០៨នេះ ជំងឺមាត់ជើងដៃបានកើតមានចំពោះកុមារចិនរហូតដល់ទៅ ២៧.៤៩៩នាក់។ ក្រៅពីប្រទេសចិនជំងឺនេះកំពុងរីករាលដាលនៅក្នុងប្រទេសវៀតណាម និងប្រទេសសិង្ហបុរីផងដែរ។ អាជ្ញាធរវៀតណាមអះអាងថា អត្រាកុមារវៀតណាមដែលកើតជំងឺប្រភេទនេះមានចំនួន ៣០០០ករណី ដែលតួរលេខនេះគឺមានការកើនឡើងលើសពីឆ្នាំ២០០៧ កន្លងទៅ។ ចំណែករដ្ឋមន្ត្រីក្រសួងសុខាភិបាលសិង្ហបុរីក៏បានអះអាងថា នៅឆ្នាំនេះ មានកុមារចំនួន ១០៤៩០នាក់ បានឆ្លងជំងឺមាត់ជើងដៃនេះដែលកើនឡើងលើសឆ្នាំទៅ៧៥ភាគរយ។**

## ជំងឺបូសអន្ទង់



Photo: P. Samphy

បើតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិតឡឹម តារា ឯកទេសវះកាត់ទូទៅនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត( ពេទ្យរុស្ស៊ី) បានឱ្យដឹងថា :

ដែលហៅថាបូសអន្ទង់ជាការធ្លាយចេញនូវផ្លូវមួយពុំធម្មតានៅបរិវេណជុំវិញរន្ធលាមក។ បូសធម្មតាជាការកខ្ទុះនៅក្នុងកន្លែងមួយបិទជិតនៅលើសាច់ដុំកន្លែងណាមួយលើរាងកាយ។ ប៉ុន្តែបូសអន្ទង់ វាគឺមានលក្ខណៈជារន្ធឆ្លងចេញចូល រវាងរន្ធក្រពេញខាងក្នុងចុងពោះធំចេញមកស្បែកខាងក្រៅ ក្បែររន្ធលាមក។បើតាមធម្មតាក្រពេញធម្មជាតិនៅចុងពោះវៀនធំ ឬរន្ធគូទ មានតួនាទីបញ្ចេញជាតិរំអិលដើម្បីជួយសម្រួលដល់ការបន្ទោបង់។ តែនៅពេលក្រពេញនោះរលាក វាគឺអាចកជាខ្ទុះរួចរកផ្លូវចេញមកខាងក្រៅតាមស្បែក។ បូសអន្ទង់ធ្វើឱ្យឈឺចាប់ដូចបូសធម្មតាដែរ ប៉ុន្តែទាល់ព្យាបាលដោយវះកាត់ត្រឹមត្រូវទើបជា ពីព្រោះវាមានទឹកលាមកហូរមករ៉ាំរ៉ៃជានិច្ច ដែលធ្វើឱ្យរំខានដល់ការរស់នៅ។

មូលហេតុ នៃបូសអន្ទង់ គឺបណ្តាលមកពីការរលាកក្រពេញដែលនៅចុងពោះវៀនធំដែលការរលាកនេះ ភាគច្រើនបណ្តាលមកពីមានការប៉ះទង្គិចខ្លាំងក្លានៅរន្ធលាមក។ ដូច្នេះអ្នកជំងឺដែលប្រឈមមុខច្រើនជាងគេ គឺអ្នកឧស្សាហ៍ទល់លាមក ស្ត្រីដែលឆ្លងទន្លេ ឬក៏បុរសរួមភេទដូចគ្នានេះឯង។

ដូច្នេះតាមអនុសាសន៍របស់លោកវេជ្ជបណ្ឌិតឡឹម តារា ដើម្បីបង្ការជំងឺបូសអន្ទង់នេះ គឺមនុស្សម្នាក់ៗគួរតែគប្បីមានរបៀបរបបរស់នៅ ឱ្យបានសមរម្យបរិភោគចំណីអាហារឱ្យមានតុល្យភាព គឺមានបន្លែផ្លែឈើច្រើន ដោយជៀសវាងបរិភោគសាច់ច្រើនពេក និងបរិភោគទឹកឱ្យបានច្រើន។ រីឯស្ត្រីត្រូវឆ្លងទន្លេ ត្រូវធ្វើជាមួយឆ្មប់ដែលមានជំនាញ។ ចំណែកបុរសមិនត្រូវរួមភេទដូចគ្នាឡើយ។ បើកើតហើយអ្នកជំងឺ គឺត្រូវប្រញាប់ទៅរកគ្រូពេទ្យជំនាញដើម្បីវិនិច្ឆ័យរោគនិងផ្តល់ការព្យាបាលឱ្យបានត្រឹមត្រូវ។

**ផាត សំភី**

June-2008.qxd 5/21/2008 11:13 AM Page 14





Photo : DR

# សំរាមប្លាស្ទិកក្លាយជាស្នាដៃសិល្បៈ និងអប់រំបរិស្ថាន

**ខាន់ ភីរម្យ**

ចាប់តាំងពីឆ្នាំ២០០៦មក នៅកម្ពុជា មានពិធីបង្ហាញម៉ូតខោអាវធ្វើអំពីសំរាមប្លាស្ទិក ដែលតែងតែឃើញគេបោះចោលនៅគ្រប់ច្រកល្ហកពាសពេញទីកន្លែងនៅក្នុងប្រទេស យ៉ាងហោចណាស់ចំនួនពីរដងធំៗ។

លោកលាង ស៊ីកន សិល្បករផ្នែកគំនូរប្រចាំនៅអង្គការគម្រោងសំរាមបានអះអាងថា ចាប់ពី ឆ្នាំ២០០៦ មកដល់ដើម ឆ្នាំ២០០៨ នេះ មានសម្លៀកបំពាក់ ៥០កំប្លេ មួក និងកាបូបមួយចំនួនត្រូវបានលោក ហើយនិងក្រុមការងារ ប្រើប្រាស់សំរាមប្លាស្ទិក យកមកកែច្នៃសម្រេចឡើង រហូតដល់មានការរៀបចំជាពិធីបង្ហាញម៉ូត ជូនភ្ញៀវទេសចរ និងសាធារណជនមើលជាច្រើនដង។

លោកបញ្ជាក់ថា : "តាំងពីពួកខ្ញុំមានគំនិតបង្កើតគម្រោងសំរាម ក្នុងឆ្នាំ២០០៦ មក មានសំរាមប្លាស្ទិកមួយចំនួន បានត្រូវពួកខ្ញុំប្រមូល យកមកធ្វើការកែច្នៃជាវត្ថុសិល្បៈផ្សេងៗមានដូចជាកាបូប មួក និងសម្លៀកបំពាក់ និងក៏បានរៀបចំពិធីបង្ហាញម៉ូតធំៗចំនួន២លើក ដែលមានការចាក់ផ្សាយតាមទូរទស្សន៍ចំនួន ២លើកផងដែរ "។

លោកបានបន្តទៀតថា គោលគំនិតនៃការកែច្នៃនេះ គឺដើម្បីចូលរួមអប់រំឱ្យប្រជាជនកម្ពុជាទាំងអស់ បានយល់ដឹង និងចេះគ្រប់គ្រងសំណល់ប្លាស្ទិក ព្រោះសំណល់ប្រភេទនេះ មានផលប៉ះពាល់យ៉ាងខ្លាំងណាស់ទៅលើបរិស្ថាន និងជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាសោភ័ណភាពរបស់ប្រទេស នាខណៈពេលដែលប្លាស្ទិក គឺជាវត្ថុដែលពេញនិយមបំផុតនៅក្នុងការប្រើប្រាស់ ប៉ុន្តែវាត្រូវបានគេគ្រវែងចោលពាសវាលពាសកាល ពេលដែលគេប្រើប្រាស់រួច។ ប្លាស្ទិកជាវត្ថុដែលមិនងាយរលាយ ហើយនឹងធ្វើប៉ះពាល់ដល់សោភ័ណភាពខ្លាំងណាស់ ប្រសិនបើពុំមានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

លោកក៏បានបញ្ជាក់ថា : "រាល់ស្នាដៃរបស់យើងគឺជាសារអប់រំមួយឱ្យពលរដ្ឋយល់ដឹងពីប្លាស្ទិក និងជំរុញឱ្យចេះគ្រប់គ្រងវា"។

លោកក៏បានបន្តទៀតថា ក្រៅពីស្នាដៃខាងលើនេះ គម្រោងសំរាមរបស់លោក ក៏បានកសាងរូបសំណាកនាគដ៏ធំមួយក្បាលអំពីសំរាមប្លាស្ទិក ដែលវាមានប្រវែងរហូតដល់ទៅ២០០ម៉ែត្រ និងក៏បានដាក់តាំងបង្ហាញចំពោះភ្ញៀវទេសចរ និងសាធារណជនជាតិ និងអន្តរជាតិ តាមដងស្ទឹង ខេត្តសៀមរាប នៅឯមុខព្រះបរមរាជវាំងដំណាក់ កាលពីថ្ងៃទី ២២ ខែមីនា កន្លងទៅនេះផងដែរ។

## អំណាន

### មាលាដួងចិត្ត




រឿង**មាលាដួងចិត្ត** គឺជាស្នាដៃទីបួនរបស់លោកនូ ហាច ដែលបោះពុម្ពដំបូងឆ្នាំ១៩៧៥ និងក៏ត្រូវបានបោះពុម្ពឡើងវិញជាច្រើនលើក។ ជាងនេះទៀត មជ្ឈមណ្ឌលឯកសារស្រាវជ្រាវ អារ្យធម៌ខ្មែរ បានបកប្រែប្រលោមលោកនេះជាភាសាបារាំង ដើម្បីជាកិច្ចផ្សព្វផ្សាយស្នាដៃអក្សរសិល្ប៍ខ្មែរលើមជ្ឈដ្ឋានអន្តរជាតិ។

**មាលាដួងចិត្ត** គឺជាស្នាដៃដ៏ប្រណីតមួយ ដែលនិយាយអំពីព្រឹត្តិការណ៍សំខាន់ៗដែលកកើតឡើងលើពិភពលោក និងកម្ពុជាក្នុងសង្គ្រាមលោកលើកទីពីរ ជាពិសេសជម្លោះរវាងខ្មែរ-ថៃ នាសម័យកាលនោះ។ តួអង្គទិយារុធគឺជាសិស្សសាលាមធ្យមសិក្សាម្នាក់ដែលពោរពេញទៅដោយមនោសញ្ចេតនាទន់ភ្លន់ និងដែលស្រលាញ់លើកតម្កើងប្រទេសជាតិ និងឱ្យតម្លៃសង្គមមួយ"បរិសុទ្ធ" ដែលមនុស្សរស់នៅក្នុងសន្តិភាព និងស្នេហាសង្គមមួយដែលគ្មានវណ្ណៈ និងគ្មានការរើសអើងជាតិសាសន៍-ល-។ (តួអង្គនេះមានសេចក្តីស្នេហាជាមួយនារីថៃ)។ ដូច្នេះ នៅចំពោះមុខបញ្ហាចាក់ស្រែះនេះ(រវាងស្នេហានិងប្រទេសជាតិ) តើទិយារុធត្រូវជ្រើសរើសផ្លូវមួយណាដើរ?

### គតិលោក



សម្រាប់អ្នកដែលចង់អប់រំផ្លូវចិត្ត ពង្រីកនូវសតិបញ្ញា និងបានយល់ដឹងអំពីពុតត្បុតគ្រប់ជំពូក ដែលមានក្នុងសង្គម គតិលោកទាំង១០ភាគ គឺអាចរាប់ជាជម្រើសដំបូងនិងល្អបំផុត។ ដោយសមត្ថភាព និងទឹកដៃសរសេរដ៏កម្ររបស់លោកឧកញ៉ាសុត្តន្ត ប្រីជាឥន្ទ កម្រងសៀវភៅទាំងនេះ ត្រូវបានបោះពុម្ពឡើងវិញជាច្រើនលើកច្រើនសា ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អ្នកអាន។ រឿងល្អៗជាច្រើនដែលយើងធ្លាប់ស្គាល់ និងឃើញក្នុងកម្មវិធីសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា គឺសុទ្ធសឹងតែស្រង់ពីកម្រងសៀវភៅទាំង១០នេះឯង: "រឿងតាថេន ចៅសន" "រឿងចចក និងទុង" និង"រឿងក្រពើ និងអ្នកបរទេះ"-ល-។ ក្នុងនោះ យើងក៏ឃើញអក្សរសិល្ប៍ បកប្រែពីល្បើកកថាដ៏ល្បីល្បាញរបស់លោកឡា ហ្វុងតែន (La Fontaine) គឺមានដូចជា "រឿងរៃ និងស្រមោច" និង "រឿងលាឈ្មោលមួយចង់ត្រាប់តាមកូនឆ្កែ"-ល-។ សៀវភៅ១ភាគៗមានប្រហែល ៨០ទំព័រ និងតំលៃ ១០០០រៀល។

**ហួត សុជាតា**

June-2008.qxd 5/21/2008 11:13 AM Page 15



# ឧសភា ឆ្នាំ១៩៦៨ ប្រទេសបារាំងរញ្ជួយ

**អាន ឡូរ៉ី ប៉ូរ៉េ**



Photo : DR

## ចលាចលមិនមែនតែនៅបារាំង!



Photo : DR

**នៅចុងបញ្ចប់នៃទសវត្សរ៍ទី៦០ នៅគ្រប់ទីកន្លែងលើពិភពលោក ប្រជាជនក្រោកឈរឡើងដើម្បីតវ៉ាប្រឆាំងនឹងសង្គ្រាមវៀតណាម និងតវ៉ាប្រឆាំងនឹងការបែងចែកពិភពលោកជាពីរប្លុក គឺលោកខាងលិច និងលោកខាងកើត។ សម្លេងបានលាន់ឮគ្រប់ទីកន្លែងដើម្បីទាមទារឱ្យប្រជាធិបតេយ្យកាន់តែត្រូវបានលើកកម្ពស់។ នៅសហរដ្ឋអាមេរិក អំពើឃាតកម្មលើអ្នកស្រីម៉ាទីន លូធឺឃីង បង្កឱ្យមានកុប្បកម្មប្រឆាំងនឹងការរើសអើងជាតិសាសន៍។ នៅប្រទេសឆេកូស្លូវ៉ាគី កងកម្លាំងសូវៀតបានបង្ក្រាបអ្នកទាមទារនូវសេរីភាពបញ្ចេញមតិ។ នៅគ្រប់ទីកន្លែងយុវជនជាអ្នកដែលបានឈរនៅជួរមុខនៃការតវ៉ា។ នៅប្រទេសចិនបដិវត្តវប្បធម៌យ៉ាងសន្ធោសន្ធៅបានផ្តល់អំណាចខាងនយោបាយដល់រដ្ឋាភិបាលផងដែរ។**

និស្សិតបះបោរ សមភូមិតាមដងផ្លូវ និងកូដកម្មជាទូទៅ ប្រទេសបារាំងបានជួបប្រទះនាខែឧសភា ឆ្នាំ១៩៦៨ នូវវិបត្តិដ៏ធំធេងមួយ ។ សព្វថ្ងៃនេះ ក៏នៅសេសសល់ជារូបថតសខ្មៅមួយចំនួនកាលពីសម័យនោះដែរ ជាពិសេសរូបថតអំពីពាក្យស្លោកដែលគេបិទលើជញ្ជាំងដែលមានន័យថាដូចជា "ហាមឃាត់ការបិទសិទ្ធិ" "សូមឱ្យមានភាពប្រាកដនិយម និងដោះស្រាយភាពមិនអាចទៅរួច" ដែលពាក្យស្លោកនេះ ក៏ត្រូវបានគេលក់ជាកាតប៉ូស្តាលផងដែរ ។

ចលាចលសង្គម ដុះដាលឡើងនៅក្នុងបរិបទ ដែលលោកឧត្តមសេនីយ៍ដឺហ្គោល មិនបានឆ្លើយតបទៅនឹងការមិនសប្បាយចិត្ត ដែលចេះតែកើនឡើងក្នុងចំណោមប្រជាជន នៅខណៈពេលដែលមានសញ្ញាទាំងឡាយក៏បង្ហាញថា ស្ថានភាពសេដ្ឋកិច្ចត្រូវបានខូចខាត ។ លោកជក់ចិត្តនឹងនយោបាយជាតិនិយមដែលសំដៅលើការពង្រឹងកិត្យានុភាពនៃប្រទេសបារាំងនៅលើឆាកអន្តរជាតិ ។ប្រព័ន្ធអប់រំលែងត្រូវតាមបទដ្ឋានទៀតហើយ : គឺមាននិស្សិតច្រើនពេកហើយរយៈពេលនៃការសិក្សាត្រូវបានបន្លាយពេលវែង ។ ជាមូលដ្ឋាន យុវជនពុំពេញចិត្តទៅនឹងវិស័យសិក្សាធិការដោយយកគំនិតតាមទស្សនវិទូនិងអ្នកនយោបាយខ្លះដូចជា ( កាល់ម៉ាក់ លេនីន និងម៉ៅ) ដោយជំទាស់នឹងអំណាចជាអាជ្ញា ( តួយ៉ាងអំណាចរបស់សាស្ត្រាចារ្យ) និងទាមទារសេរីភាពខាងផ្លូវភេទ( សិទ្ធិនៃការស្រឡាញ់គ្នាដោយសេរី និងផ្លាស់ប្តូរម៉ូដែលនៃរបៀបរស់ជាដៃគូ) ពួកគេពិភាក្សាតទល់នៅគ្រប់ទីកន្លែង ។ នេះគឺជាពេលវេលានៃការប្រឆាំង ឬមិនចំណុះ ។

ការតវ៉ាប្រឆាំងនឹងការចាប់ឃុំខ្លួននិស្សិតដែលបានធ្វើបាតុកម្មប្រឆាំងនឹងនយោបាយសហរដ្ឋអាម៉េរិកនៅវៀតណាម ក៏ធ្វើឱ្យជម្លោះកាន់តែរីកដុះដាល ។ សកលវិទ្យាល័យណង់ទែរ ជាកន្លែងនៃការប្រឆាំងតវ៉ា ត្រូវបានបិទទ្វារដោយអាជ្ញាធរ ។ អ៊ីចឹងជម្លោះបានរីករាលដាលទៅដល់សកលវិទ្យាល័យផ្សេងៗទៀត ជាពិសេសទៅកាន់សកលវិទ្យាល័យស័របោន ហើយប៉ូលីសបានចូលបង្ក្រាប ។ សង្គ្រាមទ័ពព្រៃដ៏ពិតប្រាកដបានចាប់ផ្តើមឡើងនៅទីក្រុង ។ យុវជនប្រយុទ្ធនឹងប៉ូលីសនៅតាមផ្លូវនៃទីក្រុងប៉ារីស ពួកគេបានចោលដុំថ្មទៅលើកងកម្លាំងបង្ក្រាបបាតុកម្មដែលប្រើប្រាស់ឧស្ម័នបង្ហូរទឹកភ្នែក ។ អ្នកត្រូវឃាត់ខ្លួន និងអ្នករងរបួសត្រូវបានគេរាប់ថា មានរាប់រយនាក់ ។ ចលាចលឆ្លងយ៉ាងរហ័សទៅកាន់វិទ្យាល័យទៅកាន់ទីរួមខេត្ត និងពិសេសទៅកាន់រោងចក្រ ។ អ្វីដែលជាលក្ខណៈពិសេសសម្រាប់ព្រឹត្តិការណ៍ខែឧសភាឆ្នាំ១៩៦៨ គឺការសាមគ្គីគ្នារវាងយុវជន និងកម្មករ ។ នៅចុងបញ្ចប់នៃខែឧសភានោះ ប្រជាជនបារាំងចំនួនប្រមាណ ៨លាននាក់ ស្ថិតនៅក្នុងកូដ-កម្មជាទូទៅជាមួយគ្នា ។

រដ្ឋាភិបាលបានព្យាយាមធ្វើការចរចា ។ សហជីពចុះហត្ថលេខាលើកិច្ចព្រមព្រៀង ហ្គ្រឺណែល ក្នុងខណៈពេលដែលសកម្មជនរបស់ពួកមិនចង់បាន ។ ពួកគេបានតស៊ូ តែសកម្មភាពការងារទូទៅបានចាប់ផ្តើមឡើងវិញបន្តិចម្តងៗ ។ ឧត្តមសេនីយ៍ដឺហ្គោ រំលាយសភាជាតិ ។ អំពើហិង្សាចុងក្រោយកើតមានឡើងនាពាក់កណ្តាលខែមិថុនា មួយសប្តាហ៍មុនការបោះឆ្នោត ។ ប្រធានាធិបតីដដែលនៅជាប់ឆ្នោតដោយសម្លេងលើសលប់ ។ជាការពិតនេះជាជ័យជម្នះខាងនយោបាយ ប៉ុន្តែជាមួយនឹងព្រឹត្តិការណ៍ ខែឧសភាឆ្នាំ១៩៦៨ សង្គមបារាំងក៏បានបើកចំហយ៉ាងរហ័ស និងបានផ្លាស់ប្តូរមុខមាត់របស់ខ្លួន ។




សូមថ្លែងអំណរគុណដល់ទស្សនាវដ្ដីតម្លៃនារីដែលជួយឧបត្ថម្ភទំព័រនេះ

# សេចក្ដីជូនដំណឹង!

ការិយាល័យព័ត៌មានព្រះសហគមន៍កាតូលិក នឹងមានរៀបចំការប្រឡងប្រជែងខាងគូរគំនូរលើប្រធានបទ "សិទ្ធិកុមារ" ។

លក្ខខណ្ឌចូលរួមប្រឡង : កុមារគ្រប់រូប ដែលមានអាយុពី ៨ឆ្នាំ ទៅដល់១៦ឆ្នាំ។

សូមប្អូនៗផ្ញើគំនូរមកកាន់អាសយដ្ឋានការិយាល័យយើង ឱ្យបានមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨ ខាងមុខនេះ ។

## ការងារប្រចាំខែ

- ថ្ងៃទី១៣-១៥ ឧសភា : គណៈកម្មការរបស់ព្រះសហគមន៍ផ្សារតូចរាជធានីភ្នំពេញទៅធ្វើទស្សនកិច្ចព្រះសហគមន៍បាត់ដំបង។
- ថ្ងៃទី១៩-២៤ ឧសភា : ពិធីសំណាក់របស់ធម៌លោកបូជាចារ្យទាំងបីភូមិភាគ ដែលប្រារព្ធធ្វើនៅព្រះសហគមន៍ក្រុងព្រះសីហនុ។
- ថ្ងៃទី២០ ឧសភា : មានគ្រូពេទ្យត្រចៀកជនជាតិបារាំងទៅពិនិត្យត្រចៀកជូនគ្រីស្តបរិស័ទនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី២១ ឧសភា : មានគ្រូពេទ្យត្រចៀកជនជាតិបារាំងទៅពិនិត្យត្រចៀកជូនគ្រីស្តបរិស័ទនៅព្រះសហគមន៍ក្តុលលើ ខេត្តកំពង់ចាម។
- ថ្ងៃទី២៣-២៥ ឧសភា : ជំនួប និងការចែកចាយបទពិសោធន៍ឱ្យគ្នាទៅវិញទៅមករបស់មនុស្សចាស់ដែលមានអាយុពី៤៤-៦០ឆ្នាំ ចំនួន២០នាក់ មកពីព្រះសហគមន៍តាអំ នៅព្រះសហគមន៍ខេត្តសៀមរាប។
- ថ្ងៃទី២៥ ឧសភា : យុវជនព្រះសហគមន៍សៀមរាបរៀបចំចែកអំណោយដល់អ្នកជំងឺនៅតាមមន្ទីរពេទ្យនានាក្នុងខេត្តសៀមរាប។
- ថ្ងៃទី២៥ ឧសភា : ព្រះសហគមន៍ផ្សារតូចរៀបចំកម្មវិធីទទួលព្រះកាយលើកដំបូងសម្រាប់ក្មេងៗចំនួន២៧នាក់។
- ថ្ងៃទី២៨ ឧសភា : ប្រជុំគណៈកម្មការភូមិភាគកំពង់ចាមជាមួយលោកអភិបាលបូជាចារ្យ និងគ្រីស្តបរិស័ទនៅក្នុងភូមិភាគ។
- ថ្ងៃទី១ មិថុនា : ទិវាកុមារអន្តរជាតិនៅព្រះសហគមន៍ចំការទៀង ខេត្តតាកែវ។
- ថ្ងៃទី១ មិថុនា : កម្មវិធីក្មេងៗនៅព្រះសហ-គមន៍កំពង់ចាមក្នុងឱកាសទិវាកុមារអន្តរជាតិ។
- ថ្ងៃទី២១-២២ មិថុនា : ក្រុមគ្រីស្តបរិស័ទបឹងទំពុនចំនួន ១៥នាក់ ទៅសំណាក់ធម៌នៅព្រះសហគមន៍កោះរកា ខេត្តកំពង់ចាម និងប្រជុំស្តីអំពីប្រធានបទ "ការរិះគិតអំពីព្រះគម្ពីរ"។
- ថ្ងៃទី២៧-២៩ មិថុនា : ក្រុមម៉ាជីសនៃភូមិភាគបាត់ដំបងមានរៀបចំការប្រជុំមួយដែលធ្វើនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃទី០៥-១១ កក្កដា : ការប្រជុំក្រុមម៉ាជីសនៅព្រះសហគមន៍បាត់ដំបង សៀមរាប និងភ្នំពេញ ដែលមានការចូលរួមពីសមាជិក មកពីប្រទេសអូស្ត្រាលី ៦នាក់ អាល្លឺម៉ង់ ៦នាក់ តៃវ៉ាន់ ៦នាក់ និងសមាជិកកម្ពុជា ដែលសរុបមានអ្នកចូលរួមប្រមាណ ៣០នាក់។